ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យ វ៉ាន់ដា

VANDA UNIVERSITY


## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ផលប្រយោជន៍នៃការរៀបចំឥណទានឡើងវិញ របស់ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក

# BENEFITS OF CREDIT RESTRUCTURING AT SHINHAN BANK (CAMBODIA) PLC.

## ជំនាញ គណនេយ្យ


រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យ វ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ផលប្រយោជន៍នៃការរៀបចំឥណទានឡើងវិញរបស់ ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក

BENEFITS OF CREDIT RESTRUCTURING AT SHINHAN BANK (CAMBODIA) PLC.

គ្រូណែនាំៈ លឹម សិរីរដ្ឋា

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទ៖ ផលប្រយោជន៍នៃការរៀបចំឥណទានឡើងវិញរបស់ធនាគារ**
**ស៊ិនហាន (ខេមបូឌា) ម.ក**

| | |
|---|---|
| គណៈកម្មការវាយតម្លៃទី១ | គ្រូណែនាំ |
| បេក្ខបណ្ឌិត មាស សំណាង | លឹម សិរីវដ្ឍា |
| គណៈកម្មការវាយតម្លៃទី៣ | គណៈកម្មការវាយតម្លៃទី២ |
| បេក្ខបណ្ឌិត យ៉ែម សុខហៀក | បេក្ខបណ្ឌិត យ៉ាក វុទ្ធី |
| ប្រធានគណៈកម្មការវាយតម្លៃ និងជានាយកមជ្ឈមណ្ឌលស្រាវជ្រាវ | អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករងមជ្ឈមណ្ឌលស្រាវជ្រាវ |
| បណ្ឌិត សេង សំអឿន | បេក្ខបណ្ឌិត ស្រេង ផល្លា |
| **សាកលវិទ្យាធិការ** | សាកលវិទ្យាធិការរងអចិន្ត្រៃយ៍ |
| **បណ្ឌិត ហេង វ៉ាន់ដា** | បណ្ឌិត ហ៊ូ គុជគន្ធលីនណា |

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ គណនេយ្យ នៅសាកលវិទ្យាល័យ វ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមួយមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការទាក់ទង នឹងផ្នែកហិរញ្ញវត្ថុទាំងអស់។ ជាមួយគ្នានេះដែរ ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យ វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធ នឹងការងារ គណនេយ្យ និង ហិរញ្ញវត្ថុ និងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារធនាគារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ដោយក្រុមយើងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី “**ផលប្រយោជន៍នៃការរៀបចំឥណទានឡើងវិញរបស់ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក**” យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណានិងប្រសិទ្ធភាពនៃការផ្តល់ឥណទានរបស់ធនាគារ។ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



**ឡាយ ពុធសុខលីម**
ID:HST22/030



**ម៉ុន សៅរីជាវណ្ណា**
ID:B22/2611



**ចុងសោភ័ណ្ឌា រចនា**
ID: B22/1068



**ឌិន អីវហួយ**
ID: B22/2065



**តាន់ សៀលិ**
ID:B22/2062

# **សេចក្តីថ្លែងអំណរគុណ**

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យ វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ វ៉ាន់ដាដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះគ្រូណែនាំ **លឹម សិរីវឌ្ឍា** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យ វ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អំណះអំណាង**

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យ វ៉ាន់ដា ជំនាន់ទី២២៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ “**ផលប្រយោជន៍នៃការរៀបចំឥណទានឡើងវិញរបស់ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក**” នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



ឡាយ ពុធសុខលីម

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ធនាគារ ស៊ិនហាន(ខេមបូឌា) ម.ក ត្រូវបានបង្កើតឡើងនៅទីក្រុងភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា តាំងពីខែតុលា ឆ្នាំ២០០៧ (សាខាធនាគារស៊ិនហាន នៃប្រទេសកូរ៉េ)។ ធនាគារផ្តល់ជូននូវផលប័ត្រចម្រុះនៃផលិតផល និងដំណោះស្រាយធនាគារសម្រាប់អតិថិជន និងសាជីវកម្មដែលតម្រូវតាមតម្រូវការ។ ធនាគារស៊ិនហាន បាននឹងកំពុងត្រួសត្រាយអនាគតហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាក្នុងនាមជា“First Mover” នាំមុខគេក្នុងទីផ្សារ ជាជាងធ្វើជា “Fast Follower” ដែលតស៊ូដើម្បីចាប់យកផលិតផល និងបច្ចេកវិទ្យាថ្មីៗ។

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវស្វែងយល់ដោយផ្ទាល់របស់ក្រុមយើងខ្ញុំ ទៅលើប្រធានបទ “ផលប្រយោជន៍នៃការរៀបចំឥណទានឡើងវិញរបស់ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក ” រួចមកបានធ្វើឱ្យក្រុមយើងខ្ញុំយល់ដឹងកាន់តែច្បាស់អំពីការរៀបចំឥណទានឡើងវិញរបស់ស្ថាប័ន ហិរញ្ញវត្ថុ ដោយបានផ្តល់ផលប្រយោជន៍ជាច្រើនទៅដល់ធនាគារ ជាពិសេសចំពោះអតិថិជនគ្រប់លំដាប់។ ហើយការរៀបចំឥណទានឡើងវិញនេះ ដែរត្រូវធ្វើឡើងតាមដំណាក់កាលនីមួយៗ ស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពខ្ពស់ចំពោះអ្នកផ្តល់សេវា និងអ្នកប្រើប្រាស់ផ្ទាល់។ បន្ថែមពីនេះទៀតធនាគារស៊ិនហាន (ខេមបូឌា) ម.ក ក៏បានរួមចំណែកមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សង្គមជាតិ ព្រមទាំងសេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើនផងដែរ តាមរយៈការផ្តល់ឥណទានដែលមានអត្រាការប្រាក់ទាបចូលក្នុងសេដ្ឋកិច្ចជាតិ។

ជាក់ស្តែងធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក គឺជាស្ថាប័នហិរញ្ញវត្ថុមួយដែលឈានមុខគេក្នុងការបម្រើនូវសេវាឥណទាន ជូនអតិថិជនគ្រប់លំដាប់ថ្នាក់ទូទាំងរាជធានីខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា។ ព្រមជាមួយគ្នានេះដែរ ធនាគារក៏មានបុគ្គលិកប្រកបទៅដោយចំណេះជំនាញ និងវិជ្ជាជីវៈច្បាស់លាស់ព្រមទាំងមានក្រមសីលធម៌ល្អក្នុងការបម្រើសេវាកម្មជូនអតិថិជន ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការរួមចំណែកធ្វើឱ្យធនាគារទទួលបាននូវការរីកចម្រើនឥតឈប់ឈរ ព្រមទាំងទទួលបាននូវការគាំទ្រយ៉ាងខ្លាំងពីសំណាក់សាធារណៈជនគ្រប់មជ្ឈដ្ឋាន។ ទោះបីជាធនាគារមានការរីកចម្រើនក៏ពិតមែន ប៉ុន្តែធនាគារក៏ជួបប្រទះនូវហានិភ័យមួយចំនួនផងដែរ ដែលទាមទារអោយធនាគារធ្វើការកែប្រែក៏ដូចជាបំពេញនូវចំណុចខ្វះខាតមួយចំនួនអោយបានឆាប់រហ័ស ដើម្បីអាចបំពេញនូវសេចក្តីត្រូវការរបស់អតិថិជនគ្រប់មជ្ឈដ្ឋាន។

# មាតិកា


ទំព័រ

អារម្ភកថា ........ i
រចនាសម្ព័ន្ធ ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v
មាតិកា ........ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
១.តើអតិថិជនប្រភេទណាខ្លះ ដែលត្រូវបានធនាគារ ស៊ិនហានរៀបចំឥណទានឡើងវិញ?
២.តើការរៀបចំឥណទានឡើងវិញរបស់ធនាគារ ស៊ិនហានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់អតិថិជននិងធនាគារ?
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៤.១ ទំហំដែនកំណត់ ........ ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ៣
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
១.៥.១ ប្រភពទិន្នន័យ ........ ៣
១.៥.២ ការប្រមូលទិន្ន័យបន្ទាប់ ........ ៣
១.៥.៣ វិធីសាស្ត្រវិភាគទិន្នន័យ ........ ៤
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

## ជំពូកទី២
## រំលឹកទ្រឹស្តី

២.១. លក្ខណៈទូទៅនៃការរៀបចំឥណទាន ........ ៦
២.១.១ និយមន័យឥណទាន ........ ៦
២.១.២ ប្រវត្តិឥណទាន ........ ៦
២.១.៣.ទ្រឹស្តីឥណទាន ........ ៦
២.២. លក្ខណៈទូទៅរបស់ធនាគារ ........ ៧

២.២.១ និយមន័យធនាគារ ..................................................... ៧
២.២.២ ប្រវត្តិធនាគារ ..................................................... ៧
២.២.៣ ទ្រឹស្តីរបស់ពាក់ព័ន្ធ ..................................................... ៨
២.២.៤ យុទ្ធសាស្រ្តក្នុងការរៀបចំឥណទានឡើងវិញរបស់ធនាគារ ..................................... ១៣
២.៣.លក្ខណៈទូទៅនៃការរៀបចំឥណទានឡើងវិញ ..................................... ១៤
២.៣.១.និយមន័យការរៀបចំឥណទានឡើងវិញ ..................................... ១៤
២.៣.២.ប្រវត្តិនៃការរៀបចំឥណទានឡើងវិញ ..................................... ១៤
២.៣.៣.ទ្រឹស្តីនៃការរៀបចំឥណទានឡើងវិញ ..................................... ១៥
២.៣.៤ លក្ខខណ្ឌនៃការរៀបចំឥណទានឡើងវិញ ..................................... ១៦
២.៣.៥ អត្ថប្រយោជន៍នៃការរៀបចំឥណទានឡើងវិញ ..................................... ១៧

## ជំពូកទី៣

## លទ្ធផលស្រាវជ្រាវ

៣.១ ស្ថានភាពទូទៅនៃធនាគារ ស៊ិនហាន ..................................... ១៨
៣.១.១ ប្រវត្តិរបស់ធនាគារ ស៊ិនហាន ..................................... ១៨
៣.១.២ ចក្ខុវិស័យ បេសកកម្មរបស់ធនាគាស៊ិនហាន ..................................... ១៩
ក.ចក្ខុវិស័យ ..................................... ១៩
ខ.បេសកកម្ម ..................................... ២០
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់ធនាគារ ស៊ិនហាន ..................................... ២០
ក. រចនាសម្ព័ន្ធគ្រប់គ្រង ..................................... ២០
ខ. តួនាទី និងភារកិច្ចគណៈគ្រប់គ្រង ..................................... ២១
៣.២ ប្រភេទអតិថិជនដែលធនាគារ ស៊ិនហាន ត្រូវរៀបចំឥណទានឡើងវិញ ..................................... ២១
៣.២.១ លក្ខខណ្ឌអតិថិជន ..................................... ២១
៣.២.២ យុទ្ធសាស្រ្តរបស់ធនាគារ ..................................... ២២
៣.២.៣ ដំណើរនៃការអនុម័ត ..................................... ២៣
៣.៣ ផលប្រយោជន៍នៃការរៀនចំឥណទានឡើងវិញ ..................................... ២៥
៣.៣.១ ផលប្រយោជន៍ចំពោះធនាគារ ..................................... ២៥
ក.កាត់បន្ថយហានិភ័យនៃការបាត់បង់ឥណទាន ..................................... ២៥
ខ.បន្តទំនាក់ទំនងល្អជាមួយអតិថិជន ..................................... ២៥
គ.រក្សាប្រាក់ចំណូលពីការប្រាក់ ..................................... ២៦
ឃ.បង្កើតភាពទុកចិត្តក្នុងប្រព័ន្ធហិរញ្ញវត្ថុ ..................................... ២៦
ង.បន្ថយកម្រិតឥណទានអសកម្ម ..................................... ២៦
៣.៣.២ ផលប្រយោជន៍ចំពោះអតិថិជន ..................................... ២៦
ក.បន្តសងឥណទានដោយងាយស្រួល ..................................... ២៦

ខ.បន្ថយបន្ទុកហិរញ្ញវត្ថុ ..................................................................................... ២៧
គ.បន្ធូរបន្ថយអត្រាការប្រាក់............................................................................................ ២៧
ឃ.រក្សាទំនាក់ទំនងល្អជាមួយធនាគារ.................................................................................. ២៧
ង.រក្សាប្រវត្តិឥណទានល្អ .................................................................................................. ២៨

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង........................................................................................ ២៩
៤.២ ការវិភាគលើចំណុចខ្សោយ ..................................................................................... ២៩

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........................................................................................................ ៣១
៥.២ ការផ្តល់អនុសាសន៍ .................................................................................................. ៣១

**ឯកសារយោង**
**ឧបសម្ព័ន**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

សេដ្ឋកិច្ចបានដើរតួយ៉ាងសំខាន់ចំពោះគ្រប់បណ្តាប្រទេសទាំងអស់ នៅក្នុងពិភពលោកមិនថាប្រទេសកំពុងអភិវឌ្ឍន៍ក្តី និងប្រទេសអភិវឌ្ឍន៍ក្តី។ តួយ៉ាងវិស័យហិរញ្ញវត្ថុត្រូវបានចាត់ទុកជាវិស័យមួយដ៏សំខាន់ក្នុងការរួមចំណែកជួយស្តារ ជួយជំរុញកំណើនពាណិជ្ជកម្ម និងការវិនិយោគដែលធ្វើអោយសេដ្ឋកិច្ចមានការរីកចម្រើន។ កាលណាប្រទេសជាតិមួយមានសុខសន្តិភាព គ្មានសង្គ្រាម គ្មានបាតុកម្ម កូដកម្ម គ្រោះធម្មជាតិ និងជំងឺរាតត្បាតនានាវា ក៏ជាចំណែកមួយនៅក្នុងការជួយសេដ្ឋកិច្ចហិរញ្ញវត្ថុរបស់ប្រទេសនោះផងដែរ។ ប៉ុន្តែប្រសិនបើសេដ្ឋកិច្ចក្នុងប្រទេសមួយមានការធ្លាក់ចុះវិញនោះ គឺវានឹងជះឥទ្ធិពលយ៉ាងខ្លាំងចំពោះគ្រប់វិស័យទាំងអស់ ដូចជាក្រុមហ៊ុនអាជីវកម្ម រោងចក្រ កសិកម្ម និងឧស្សាហកម្មត្រូវបានជាប់គាំង និងប្រឈមមុខទៅនឹងការបិទទ្វា ឬក្ស័យធន ដែលជាហេតុបង្កហានិភ័យទៅដល់ប្រជាពលរដ្ឋ ធ្វើឱ្យប្រជាពលរដ្ឋគ្មានការងារធ្វើ បាត់បង់នូវប្រាក់ចំណូល ជាពិសេសចំពោះអ្នកដែលមានបំណុលត្រូវទូទាត់រៀងរាល់ខែ ឬរាល់ឆ្នាំ។

វិស័យសេដ្ឋកិច្ច ជាគ្រឹះដ៏សំខាន់សម្រាប់គ្រប់បណ្តាប្រទេសទាំងអស់នៅលើពិភពលោក។ ក្នុងនោះវិស័យហិរញ្ញវត្ថុត្រូវបានចាត់ទុកជាកម្លាំងចលករដ៏សំខាន់ក្នុងការជំរុញកំណើនពាណិជ្ជកម្ម និងវិនិយោគដែលជាកត្តារួមចំណែកដល់ការរីកចម្រើនសេដ្ឋកិច្ច។ សុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសង្គម និងអវត្តមាននៃគ្រោះមហន្តរាយនានា គឺជាកត្តាគាំទ្រយ៉ាងសំខាន់ដល់សុខភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ប្រទេសនីមួយៗ។ ផ្ទុយទៅវិញ បើមានការធ្លាក់ចុះសេដ្ឋកិច្ចអាចនាំមកនូវផលវិបាកយ៉ាងធ្ងន់ធ្ងរដល់គ្រប់វិស័យ ទាំងអស់ដែលអាចប្រឈមមុខនឹងការជាប់គាំង ឬក្ស័យធន។ ផលប៉ះពាល់អវិជ្ជមានទាំងនេះ នឹងបង្កឱ្យមានហានិភ័យដល់ប្រជាពលរដ្ឋ តាមរយៈការបាត់បង់ការងារ ប្រាក់ចំណូល និងជាពិសេស សម្រាប់អ្នកដែលមានបំណុលត្រូវសងជាប្រចាំ។

ជាការពិតណាស់ ដោយមើលឃើញពីបញ្ហានេះហើយទើបធនាគារជាតិចេញសារាចរណែនាំស្តីពី ការរៀបចំឥណទានឡើងវិញ ក្នុងគោលបំណងរក្សាស្ថេរភាពហិរញ្ញវត្ថុ និងគាំទ្រសកម្មភាពសង្គម ជាពិសេសដើម្បីជួយសម្រួលដល់អ្នកខ្ចីប្រាក់ដែលកំពុងប្រឈមនឹងការធ្លាក់ចុះនៃប្រាក់ចំណូលចម្បង និងមានការលំបាកក្នុងការទូទាត់សងទៅដល់ស្ថាប័នហិរញ្ញវត្ថុវិញ។

ដើម្បីយល់ដឹងពីបញ្ហាទាំងនេះអោយកាន់តែច្បាស់និងស៊ីជម្រៅបន្ថែមទៀតនោះទើបក្រុមនាងខ្ញុំបានសម្រេចជ្រើសរើសប្រធានមួយដែលស្តីពី "**ផលប្រយោជន៍នៃការរៀបចំឥណទានឡើងវិញរបស់ស្ថាប័នហិរញ្ញវត្ថុ**" យកមកសិក្សាស្រាវជ្រាវនិងរៀបចំចងក្រងជាសៀវភៅដើម្បីអោយក្រុមនាងខ្ញុំទទួលនូវចំណេះដឹងថ្មីៗបន្ថែមទៀត។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

បន្ទាប់ពីធនាគារជាច្រើនស្ថាប័ននៃកម្ពុជាបានចេញសារាចរណែនាំស្តីពីការរៀបចំឥណទានឡើងវិញកាលពីថ្មីៗនេះ ជាលទ្ធផលបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ប្រជាពលរដ្ឋ និងសេដ្ឋកិច្ចជាតិ ពិសេសនៅក្នុងអំឡុងពេលប្រជាពលរដ្ឋជួបផលលំបាកក្នុងការរកប្រាក់ចំណូលដោះស្រាយជីវភាពប្រចាំថ្ងៃខណៈពេល

ដែលសេដ្ឋកិច្ចពិភពលោកនៅមិនទាន់មានភាពប្រាកដប្រជាដែលកំពុងបង្កផលលំបាកដល់បណ្តាប្រទេសមួយចំនួនជុំវិញពិភពលោក។

ដើម្បីងាយស្រួលក្នុងការប្រមូលគោលគំនិតសម្រាប់ធ្វើការស្រាវជ្រាវ ក្រុមសារណាស្រាវជ្រាវនាងខ្ញុំនឹងធ្វើការសិក្សាស្រាវជ្រាវពីរចំណុចដូចខាងក្រោម៖

១.តើអតិថិជនប្រភេទណាខ្លះ ដែលត្រូវបានធនាគារ ស៊ិនហានរៀបចំឥណទានឡើងវិញ?

២.តើការរៀបចំឥណទានឡើងវិញរបស់ធនាគារ ស៊ិនហានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់អតិថិជន និងធនាគារ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

- ដើម្បីយល់ដឹងមូលហេតុនៃការធ្វើឥណទានឡើង
- ដើម្បីយល់ដឹង ពីគោលការណ៍និងដំណើរការនៃការរៀបចំឥណទានឡើងវិញ
- ដើម្បីយល់ដឹង គោលការណ៍ដែលជាមូលដ្ឋាននៃការរៀបចំឥណទានឡើងវិញ រួមទាំងលក្ខខណ្ឌ និងប្រភេទនៃការរៀបចំផ្សេងៗ
- ដើម្បីយល់ដឹងពីដំណើរការទាំងមូលចាប់ពីចាប់ផ្តើម រហូតដល់ការអនុម័ត និងការអនុវត្ត
- ដើម្បីយល់ដឹងបន្ថែមទៀតពីផលប្រយោជន៍ ដែលអតិថិជនអាចទទួលបានពីការរៀបចំឥណទានឡើងវិញ
- ដើម្បីយល់ដឹង និងចេះវិភាគអំពីផលប៉ះពាល់នៃការរៀបចំឥណទានឡើងវិញទៅលើស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន និងស្ថាប័នហិរញ្ញវត្ថុដើម្បីបំពេញបន្ថែមចំណេះដឹងអំពីវិស័យហិរញ្ញវត្ថុ និងឥណទាន។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ក្នុងការស្រាវជ្រាវនេះយើងធ្វើការសិក្សាលម្អិតទៅលើការផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារឯកជនជួយអតិថិជនក្នុងការបង់ប្រាក់មានភាពធូរស្រាលជាងមុនមានន័យថាពីមុនអតិថិជនមានកាតព្វកិច្ចបង់ប្រាក់នៅពេលដែលអតិថិជនជួបវិបត្តិធ្លាក់ចំណូលនោះនឹងមានការស្នើឲ្យរៀបចំឥណទានឡើងវិញដូច្នេះគ្រឹះស្ថានធនាគារនិងសម្រួលជួយអតិថិជនដោយអនុញ្ញាតឱ្យបង់ទៅតាមលទ្ធភាពរបស់អតិថិជនដែលមាន។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ដំណើរការនៃការស្រាវជ្រាវនេះ គឺធ្វើឡើងបង្ហាញពីវិធីសាស្ត្រនៃការរៀបចំឥណទានឡើងវិញរបស់គ្រឹះស្ថានធនាគារស៊ីនហាន ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ទិន្នន័យទាំងអស់ដែលយើងទទួលបាននេះគឺធ្វើឡើងដោយវិធីសាស្ត្រ៣យ៉ាង ដូចខាងក្រោម៖

### ១.៥.១ ប្រភពទិន្នន័យ

- **សិក្សាស្រាវជ្រាវតាមរយៈឯកសារ និងគំនិតយោបល់ដែលបានផ្តល់ដោយ លោកសាស្ត្រាចារ្យដឹកនាំក្រុម៖** គឺតាមរយៈចំណេះដឹង និងឯកសារនានាដែលទទួលបាន គឺសាស្ត្រាចារ្យទាំងអស់នៃវិទ្យាស្ថានវ៉ាន់ដា ដែលបានផ្តល់ក្នុងរយៈពេលដែលបានសិក្សា កន្លងមក។

- **ស្រាវជ្រាវតាមរយៈការអានគោលនយោបាយនានា** របស់ធនាគារស៊ិនហាននិង របាយការណ៍លទ្ធផលនានា ដែលបានបោះផ្សាយដោយធនាគារស៊ិនហានផ្ទាល់។
- **សិក្សាស្រាវជ្រាវនៅបណ្ណាល័យតាមរយៈ** និក្ខេបបទ និងរបាយការណ៍កម្មសិក្សាដែលបានជាស្នាដៃរបស់រៀមច្បងដោយធ្វើការដកស្រង់និងស្វែងយល់បន្ថែមតាមរយៈឯកសារស្រាវជ្រាវចាស់ៗ ដែលបានស្រាវជ្រាវកន្លងមកនៅក្នុងបណ្ណាល័យនៃ **សាកលវិទ្យាល័យ វ៉ាន់ដា** ។
- **សិក្សាស្រាវជ្រាវតាមរយៈប្រព័ន្ធអ៊ីនធើណេត** ធ្វើការស្រាវជ្រាវតាមរយៈគេហទំព័រនានា ដែលបានបោះផ្សាយឯកសារ និងមានពាក់ព័ន្ធទៅនឹងប្រធានបទ។

### ១.៥.២ វិធីសាស្ត្រប្រមូលទិន្នន័យ

#### ក. ទិន្នន័យចម្បង

ទិន្នន័យចម្បងជាទិន្នន័យដែលប្រមូលបានទាំងស្រុងពីធនាគារៈ

- ទិន្នន័យដែលទទួលបានតាមរយៈ ធ្វើកិច្ចសម្ភាសន៍ជាមួយមនុស្សសំខាន់ៗនៅក្នុងស្ថាប័ន
- ទិន្នន័យទទួលបានតាមរយៈធ្វើការចុះកម្មសិក្សាផ្ទាល់និងការសន្ទនាតាមទូរស័ព្ទទៅកាន់ថ្នាក់ដឹកនាំនិងសាកសួរជាមួយមន្ត្រីឥណទាននៅក្នុងធនាគារ។
- ជាទិន្នន័យដែលទទួលបានពីការចុះកម្មសិក្សាស្រាវជ្រាវផ្ទាល់នៅធនាគារស៊ិនហានតាមរយៈ ការសង្កេតលើការអនុវត្តការងារជាក់ស្តែងរបស់មន្ត្រីឥណទានក្នុងគោលការណ៍នៃការផ្តល់ឥណទានខ្នាតតូចនិងមធ្យមរបស់ធនាគារស៊ិនហានដែលបានសម្ភាសន៍ជាមួយក្រុមការងាររបស់ធនាគារ និងតាមរយៈកម្រងសំណួរស្រាវជ្រាវ។

#### ខ. ទិន្នន័យបន្ទាប់បន្សំ

- ទិន្នន័យដែលទទួលបានតាមរយៈGoogle, Facebook, Website, SINHAN BANK
- តាមរយៈការផ្តល់ព័ត៌មានពីអតិថិជនដែលទទួលប្រាក់កម្ចី
- តាមរយៈការសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យ
- តាមរយៈមេរៀនដែលបានសិក្សាកន្លងមក
- តាមរយៈទិន្នន័យមានស្រាប់ដែលបានបោះពុម្ពផ្សាយជាទ្រឹស្តី ក្នុងការផ្តល់ឥណទាន កន្លងមក ជាពិសេសបានមកពីសាស្ត្រាចារ្យដឹកនាំប្រគល់ឲ្យមួយចំនួន និងរបាយការណ៍ដែលមាននៅក្នុងបណ្ណាល័យនៃ សាលកវិទ្យាល័យ វ៉ាន់ដា។

### ១.៥.៣ វិធីសាស្ត្រវិភាគទិន្នន័យ

ក្នុងការវិភាគទិន្នន័យនេះ គឺយើងខ្ញុំបានវិភាគតាមបរិមាវិស័យ( Quantitative ) ដោយបានលើកយកលទ្ធផលនៃគម្រោងសំណួរដែលបានដាក់ឲ្យខាងធនាគារដើម្បីត្រួតពិនិត្យ គឺទិន្នន័យមានស្រាប់ដែលពាក់ព័ន្ធលើកយកមកវិភាគ ហើយធ្វើការផ្ទៀងផ្ទាត់ គឺប្រៀបធៀបគ្នារវាងមតិយោបល់របស់ថ្នាក់ដឹកនាំនឹងការចុះជួបផ្ទាល់ថាតើវាមានភាពខុសគ្នាយ៉ាងណា ? ហើយបន្ទាប់មកធ្វើការប្រៀបធៀបពីការដកស្រង់ចេញពីសៀវភៅ ដែលបានសិក្សារួចមក និងការពន្យល់ណែនាំពីសាស្ត្រាចារ្យដឹកនាំស្រាវជ្រាវរួមទាំងឯកសារដែលបានមកពីបណ្ណាល័យ និងអ៊ិនធើណេតផងដែរ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាទៅលើប្រធានបទផលប្រយោជន៍នៃការរៀបចំឥណទានឡើងវិញរបស់ធនាគារស៊ិនហាន គឺបានស្វែងយល់ពីទ្រឹស្តី និងបានចុះកម្មសិក្សាដោយផ្ទាល់ជាមួយធនាគារ។ ដូច្នេះការអនុវត្តជាក់ស្តែងបានបង្ហាញឲ្យឃើញថាចំណេះដឹងដែលបានមកពីការសិក្សាទ្រឹស្តីបទ បានជាបទពិសោធន៍ក្នុងការធ្វើនិក្ខេបបទរបស់ក្រុមយើងខ្ញុំ។ ចំពោះប្រធានបទនៃនិក្ខេបបទនេះនឹងបានផ្តល់ជាប្រយោជន៍ជាច្រើនដូចខាងក្រោម៖

- **សម្រាប់ធនាគារស៊ិនហាន៖** ជាការជួយផ្សព្វផ្សាយពាណិជ្ជកម្មសេវាកម្ម ជូនដល់អតិថិជន និងសាធារណជន។ លើកឡើងនូវ គុណវិបត្តិនិងគុណសម្បត្តិដំណើរការប្រតិបត្តិការ។ បង្កើនភាពជឿជាក់ដល់អតិថិជនលើសេវាកម្ម របស់ស្ថាប័នហិរញ្ញវត្ថុ។ ចូលរួមផ្តល់អនុសាសន៍មួយចំនួនដែលពាក់ព័ន្ធនឹងចំណុចខ្វះខាតដែលជាឯកសារសម្រាប់ផ្សព្វផ្សាយសេវាកម្មរបស់ខ្លួន។
- **សម្រាប់អតិថិជន៖** ឯកសារជំនួយដល់អតិថិជនឲ្យបានយល់ដឹងច្បាស់ពីការផ្តល់ឥណទាន។ បានយល់ច្បាស់ពីអត្ថប្រយោជន៍នៃការប្រើប្រាស់ឥណទាន។
- **សម្រាប់សមាជិកស្រាវជ្រាវ៖** ពង្រឹងសមត្ថភាពយល់លើផ្នែកទ្រឹស្តី និងបទពិសោធន៍លើវិស័យហិរញ្ញវត្ថុនិងធនាគារដោយបង្ហាញ នូវសាមគ្គីភាពនិងសហការគ្នាសម្រាប់សមាជិកស្រាវជ្រាវ។ បានផ្តល់ជាឯកសារសម្រាប់និស្សិត ជំនាន់ក្រោយៗ យល់ដឹងពីដំណើរការនៃការផ្តល់ឥណទានទៅលើវិស័យធនាគារ។
- **សារៈសំខាន់សង្គមជាតិ៖** កាលណាមានអ្នកស្រាវជ្រាវកាន់តែច្រើន ប្រជាពលរដ្ឋក៏មានចំណេះដឹងខ្ពង់ខ្ពស់កាន់តែកើនឡើងដែរពីព្រោះសម្បូរទៅដោយឯកសារស្រាវជ្រាវសម្រាប់យុវជនជំនាន់ក្រោយៗធ្វើការស្រាវជ្រាវបន្ត។ធនាគារមានភាពរីកចម្រើន វាធ្វើអោយប្រកពទុនមានការកើនឡើងដែលជម្រុញអោយមានការវិនិយោគកាន់តែច្រើនតាមរយៈការផ្តល់ប្រាក់កម្ចីទៅប្រជាជនសម្រាប់អាជីវកម្ម។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវយើងចែកចេញជា៥ជំពូកដូចខាងក្រោម៖

- **ជំពូកទី១៖** លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- **ជំពូកទី២៖**ផលប្រយោជន៍នៃការរៀបចំឥណទានឡើងវិញរបស់ធនាគារ
- **ជំពូកទី៣៖** ផលប្រយោជន៍នៃការរៀបចំឥណទានឡើងវិញរបស់ធនាគារ ស៊ិនហាន
- **ជំពូកទី៤៖** ការវិភាគអំពីចំណុចខ្លាំង និងចំណុចខ្សោយ នៅក្នុងធនាគារបន្ទាប់ពីបានសិក្សាស្រាវជ្រាវរួចមក។
- **ជំពូកទី៥៖** ការសន្និដ្ឋាន និង ផ្តល់អនុសាសន៍ផ្សេងៗអំពីចំណុចខ្វះខាតនៅក្នុងធនាគារ។

# ជំពូកទី២

# ផលប្រយោជន៍នៃការរៀបចំឥណទានឡើងវិញរបស់ស្ថាប័នហិរញ្ញវត្ថុ

## ២.១. លក្ខណៈទូទៅនៃការរៀបចំឥណទាន

### ២.១.១ និយមន័យឥណទាន

ឥណទាន(Credit) គឺជាការឲ្យខ្ចីប្រាក់ដែលមានចងជាកិច្ចសន្យាត្រឹមត្រូវ ហើយអ្នកខ្ចីប្រាក់មានកាតព្វកិច្ចប្រើប្រាស់ប្រាក់កម្ចីឱ្យបានស្របច្បាប់ និងសងត្រលប់មកវិញនូវប្រាក់ដើមការប្រាក់ និងបន្ទុកហិរញ្ញវត្ថុផ្សេងៗទៀតដែលមានចែងកិច្ចសន្យាឲ្យបានទៀងទាត់[1]។

ឥណទាន(Credit) គឺជាផ្តល់កម្ចីទៅឱ្យនរណាម្នាក់ដោយមានការព្រមព្រៀងគ្នាត្រូវតែគោរពទៅតាមកិច្ចសន្យានោះដោយត្រូវសងត្រឡប់មកវិញ ទាំងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យឱ្យទាន់ពេលវេលាដោយច្បាស់លាស់ជាក់ស្តែងជាក់លាក់[2]។

ឥណទាន(Credit) គឺជាចំនួនទឹកប្រាក់ដែលធនាគារផ្តល់ឱ្យអតិថិជន ដែលតម្រូវឱ្យពួកគេត្រូវសងត្រឡប់មកវិញនូវប្រាក់ដើម និងការប្រាក់តាមពេលវេលាកំណត់ណាមួយ[3]។

### ២.១.២ ប្រវត្តិឥណទាន

ឥណទានបានចាប់ផ្តើមនៅឆ្នាំ ១៩៨៧ ដោយអង្គការ UNICE ដែលការចាប់ផ្តើមនេះបានផ្តល់ជារបៀបឥណទានសត្វគោ ព្រោះថាក្រោយពីសង្គ្រាមរួមមកបានបន្សល់ទុកនៅស្ត្រីមេម៉ាយ ចាស់ជរា ក្មេងកំព្រាជាច្រើនដែលជាមេគ្រួសារ ហើយពួកគេមានការខ្វះខាតកម្លាំងពលកម្មបុរស និងកម្លាំងអូសទាញសម្រាប់ការងារកសិកម្ម។

នៅឆ្នាំ ១៩៩១ អង្គការ GRET (Group Exchange des Technique) ដែលទទួលឥណទានពីភ្នាក់ងារអភិវឌ្ឍន៍នៃប្រទេសបារាំង ( Agene Francoise de Development ) បានបង្កើតអង្គការមួយដែលមានឈ្មោះថាអង្គការមូលដ្ឋានឥណទាន។

អង្គការនេះបានចាប់ផ្តើមសាកល្បងឥណទានរបស់ខ្លួនដំបូងនៅក្នុងស្រុកកំពុងត្របែក ខេត្តព្រៃវែង។ អេស៊ីលីដា សិលាលីមីធីត ស្ថាបនាសហគ្រិន...រហូតមកដល់សព្វថ្ងៃ។ក្រោយៗមកមានធនាគារ និងអង្គការជាច្រើនបានចូលរួមចំណែកប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ដូចជា ធនាគារ[4]។

### ២.១.៣.ទ្រឹស្តីឥណទាន

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា គឺបានអភិវឌ្ឍន៍យ៉ាងឆាប់រហ័សនៅពេលដែលសេដ្ឋកិច្ចរីកចម្រើនប្រជាពលរដ្ឋមានចំណូលកម្រិតមធ្យមក៏កើនឡើងផងដែរ។ កំណើននេះបានធ្វើឲ្យមាន ការផ្លាស់ប្តូរបែបបទរស់នៅរបស់ពួកគេ។ កំណើនប្រាក់ចំណូលរបស់គ្រួសារនីមួយៗធ្វើឲ្យអតិថិជនមានកំណើន តម្រូវការសេវាឥណទានផ្សេងៗ ហើយកម្ពុជានៅប៉ុន្មានឆ្នាំចុងក្រោយនេះ មានសន្ទុះនៃការវិនិយោគលើវិស័យអចលនទ្រព្យមានការកើនឡើងយ៉ាងខ្លាំង ដោយមានបណ្តាខេត្តមួយចំនួនគេសង្កេតឃើញមានអាគារខ្ពស់ៗ សំណង់ដែលមានទឹកប្រាក់វិនិយោគរាប់រយលានដុល្លារ គ្របដណ្តប់ស្ទើរពេញខេត្តក្រុងនៃផ្ទៃប្រទេស។

---

[1] TOLA Banking. (2020, July 5). *តើឥណទានជាអ្វី?* Retrieved from https://www.facebook.com/share/p/1DkDcay5MB/

[2] PANHA KH. (2020, October 25). *និយមន័យឥណទាន?* Retrieved from https://youtu.be/z35JVQNSHx8?si=nadf_TTNOi778LSZ, (2025, September 15)

3 វិទ្យាស្ថានវ៉ាន់ដា. (២០១៧). *សៀវភៅរូបិយវត្ថុ និងធនាគារ.* បោះពុម្ពឆ្នាំ២០១៧. ទំព័រទី២

[4] ហេង ប៊ុននី ,លឿន គាគ្គា, កែវ សានីត, ហ៊ុល ហៀងម៉ូនីតា, តិល ធារ៉ា. (ឆ្នាំ២០២២). ដំណឹងននៃការផ្តល់ឥណទានរបស់ធនាគារឯកទេសឌីជីបី. សារណាថ្នាក់បរិញ្ញបត្រជំនាន់ទី១៩ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា ទំព័រទី៨។

ទន្ទឹមគ្នានោះដែរ កម្ចីនៃបណ្តាធនាគារ ក្រុមហ៊ុនភិតសន្យា ក៏ដូចជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន ក៏មានការកើនឡើងច្រើនផងដែរ។ កម្ចីខ្លះខ្ចីក្នុងគោលបំណងប្រើប្រាស់ផ្ទាល់ខ្លួន ខ្លះខ្ចីក្នុងគោលបំណងវិនិយោគលើដីធ្លី និងផ្ទះនៅតំបន់អភិវឌ្ឍន៍[5]។

## ២.២. លក្ខណៈទូទៅរបស់ធនាគារ

### ២.២.១ និយមន័យធនាគារ

ធនាគារ គឺជាស្ថាប័នហិរញ្ញវត្ថុមួយ ដែលទទួលប្រាក់បញ្ញើ ដើម្បីដកតាមតម្រូវការ( ដូចជាសរសេរមូលប្បទានបត្រ ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច ) ហើយនឹងផ្តល់ឥណទានទៅឲ្យសាធារណៈជន និងអាជីវកម្ម( ផ្តល់ឥណទានដល់អាជីវកម្មឯកជន ដើម្បីពង្រីកសន្និធិរបស់ទំនិញនៅក្នុងហាងរបស់ពួកគេ ឬដើម្បីទិញសម្ភារៈបរិក្ខាថ្មីៗ ) [6]។

ធនាគារគឺជា ស្ថាប័នហិរញ្ញវត្ថុមួយ ដែលទទួលបញ្ញើសាធារណៈ និង ផ្តល់តម្រូវការដាក់ប្រាក់ ខណៈពេលបង្កើតជាកម្ចីសម្រាប់សាធាណៈជន។ ធនាគារអាចប្រតិបត្តិការ សកម្មភាពកម្ចីដោយផ្ទាល់ ឬដោយប្រយោលបាន តាមរយៈទីផ្សារមូលធន ហើយ ស្ថាប័ននេះដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការរក្សាស្ថេរភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរបស់ប្រទេសមួយ[7]។

ធនាគារ គឺជាអន្តរការីហិរញ្ញវត្ថុដែលផ្តល់នូវសេវាកម្មផ្នែកហិរញ្ញវត្ថុយ៉ាងទូលំទូលាយជាពិសេស ការផ្តល់ឥណទាន ការទទួលប្រាក់បញ្ញើ ការបម្រើសេវាកម្មទូទាត់ និងអនុវត្តន៍នូវមុខងារហិរញ្ញវត្ថុនៃក្រុមហ៊ុនសាជីវកម្ម ក្នុងសេដ្ឋកិច្ច[8]។

### ២.២.២ ប្រវត្តិធនាគារ

តាមរយៈធ្វើវិសោធនកម្មដោយប្រកាសៈ ធ៧-០៦-២០៧ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ, ធ៧-០៤-២០៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ស្តីពី សោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធ៧-០១-១៨៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ ២០០១ ស្តីពី ផ្ទេរភាគហ៊ុនរបស់ធនាគារ និង ធ៧-០១-១៣៦ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ស្តីពីប្រាក់ តំកល់ជានាលើដើមទុន. ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការកំណត់ជាថ្មីនូវដើមទុន ចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ។ធនាគារពាណិជ្ជ តទៅនេះហៅថាធនាគារ ដូចមានកំណត់និយមន័យក្នុងជំពូកទី ១ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា មុនពេលចាប់ផ្តើមធ្វើប្រតិបត្តិ ការអនុលោមតាមមាត្រា ១៤នៃច្បាប់ដដែលនេះ។អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណធនាគារត្រូវប្រកាន់យកនូវរូបភាពគតិយុត្តណាមួយ ក្នុងចំណោមរូបភាពគតិយុត្តដែលមានចែងក្នុងជំពូកទី ៣ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ (ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨) ធនាគារពាណិជ្ជបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុន ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិច មួយជាគ្រឹះស្ថាន

[5] ហេង ប៊ុននី ,លឿន គាត្ថា, កែវ សានីត, ហ៊ុល ហៀងម៉ូនីតា, តិល ជាក់. (ឆ្នាំ២០២២). ដំណឹងននៃការផ្តល់ឥណទានរបស់ធនាគារឯកទេសឌីជីបី. សារណាថ្នាក់បរិញ្ញាបត្រជំនាន់ទី១៩ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា ទំព័រទី១០។

[6] ACADEMIA. Ory Kalip Ory Kalip. (2020, July 20). *និយមន័យធនាគារ.* Retrieved from https://www.academia.edu/31513027/និយមន_យធនាគារ

[7] ហេង ប៊ុននី ,លឿន គាត្ថា, កែវ សានីត, ហ៊ុល ហៀងម៉ូនីតា, តិល ជាក់. (ឆ្នាំ២០២២). ដំណឹងននៃការផ្តល់ឥណទានរបស់ធនាគារឯកទេសឌីជីបី. សារណាថ្នាក់បរិញ្ញាបត្រជំនាន់ទី១៩ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា ទំព័រទី៦។

[8] ហេង ប៊ុននី ,លឿន គាត្ថា, កែវ សានីត, ហ៊ុល ហៀងម៉ូនីតា, តិល ជាក់. (ឆ្នាំ២០២២). ដំណឹងននៃការផ្តល់ឥណទានរបស់ធនាគារឯកទេសឌីជីបី. សារណាថ្នាក់បរិញ្ញាបត្រជំនាន់ទី១៩ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា ទំព័រទី៦។

ធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការវាយតម្លៃ ចំណាត់ថ្នាក់វិនិយោគ ដោយ ភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ៥០,០០០,០០០,០០០ រៀល (ហាសិបពាន់លានរៀល)។ ចំពោះធនាគារពាណិជ្ជដែលមានភាគទុនិកជាវិនិយោគិនដែលជាឯកត្តជនឬក្រុមហ៊ុនត្រូវមានដើមទុនអប្បបរមាស្មើនឹង ១៥០.០០០.០០០.០០០ រៀល (មួយរយហាសិបពាន់លាន រៀល)[៩]។

**២.២.៣ ទ្រឹស្តីរបស់ពាក់ព័ន្ធ**

នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាប័ណ្ណរបស់ធនាគារ ត្រូវស្នើរដោយបុគ្គល ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ (អ្នកចាត់ការ ឬ ជនដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ) ស្របតាមបទប្បញ្ញត្តិដែលមានរៀបរាប់ខាងក្រោមនេះ ៖

- នាម ឬ នាមករណ៍អាជីវកម្មរបស់គ្រឹះស្ថាន
- អាសយដ្ឋាននៃទីស្នាក់ការកណ្តាល ឬសាខានៅកម្ពុជាក្នុងករណីជាក្រុមហ៊ុនបរទេស
- រូបភាពគតិយុត្តនិងលក្ខន្តិកៈ ឬឯកសារបង្កើតផ្សេងៗទៀត
- ប្រភេទមូលបត្រ័តំណាងឱ្យដើមទុន និងចំណងទាក់ទងរវាងការកាន់កាប់មូលប័ត្រទាំងនោះ និងការអនុវត្តន៍សិទ្ធិបោះឆ្នោត
- ចំនួនដើមទុនដែលមានស្រាប់ ឬដើមទុនដែលបានគ្រោង ឬចំនួនដើមទុនដែលត្រូវបង់ក្នុង ករណីជាសាខាក្រុមហ៊ុនបរទេសក្នុងប្រការ៣ នៃប្រកាសនេះចំនួននេះយ៉ាងតិចបំផុតត្រូវស្មើនឹងចំនួនដើមទុនដែលមានចែង
- ការបែងចែកភាគហ៊ុន និងសិទ្ធិបោះឆ្នោត និងកិច្ចព្រមព្រៀងដែលអាចមានរវាងភាគទុនិកៈដែល ដើរតួនាទីក្នុងការដឹកនាំគោលនយោបាយរបស់ធនាគារ
- ភាគទុនិកៈដែលកាន់កាប់ប្រាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោតឬលើសពីនេះ ត្រូវផ្តល់ព័ត៌មាន ដូចមានរៀបរាប់ក្នុងប្រការ ៥ នៃប្រកាសនេះ
- អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិចបំផុតពីររូប (២រូប) ដែលទទួលខុសត្រូវក្នុងការដឹកនាំដោយ មានប្រសិទ្ធភាពនូវសកម្មភាពអាជីវកម្មរបស់ធនាគារ។ អ្នកចាត់ការដែលបានទទួលការតែងតាំង ហើយខាងលើនេះត្រូវផ្តល់ព័ត៌មានដូចមានរៀបរាប់នៅប្រការ ៦ នៃប្រកាសនេះ ហើយផ្តល់នូវ លិខិតថ្កោលទោសមួយច្បាប់។ ចំពោះអ្នកចាត់ការជាជនបរទេសដែលមានលំនៅដ្ឋាននៅកម្ពុជាតិចជាងបីឆ្នាំ (៣ឆ្នាំ) លិខិតថ្កោលទោសនេះត្រូវជំនួសដោយឯកសារចេញដោយអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសដើមរបស់ខ្លួនដោយមានបញ្ជាក់ថាជនដែលមានពាក់ព័ន្ធមិនត្រូវបានហាមឃាត់មិនឱ្យចាត់ចែកការងារក្នុងគ្រឹះស្ថានហិរញ្ញវត្ថុណាមួយតាមខ្លឹមសារនៃបទប្បញ្ញត្តិរបស់ប្រទេសនោះទេ។អ្នកចាត់ការសាខាធនាគារបរទេសនៅកម្ពុជា ត្រូវបានតែងតាំងដោយអ្នកមានសមត្ថកិច្ចនៅទីស្នាក់ការកណ្តាល។
- អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាល បន្ថែមពីលើព័ត៌មានខាងលើ ត្រូវមានជីវប្រវត្តិ និង ត្រូវឆ្លើយសំនួរដូចមានក្នុងឧបសម្ព័ន្ធទី៤ ព្រមទាំងត្រូវមានរបាយការណ៍បញ្ជាក់ថាគ្មាននរណា ម្នាក់ពាក់ព័ន្ធទៅនឹងការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុ សមាជិក

[៩] ធនាគារជាតិនៃកម្ពុជា. (២០២៤). *ប្រវត្តិធនាគារ?* Retrieved from https://www.nbc.gov.kh/download_files/legislation/prakas_kh/1031b7-00-04.pdf ទំព័រ ៣៧៦

ក្រុមប្រឹក្សាភិបាលត្រូវមានបទពិសោធន៍ខាងឥណទានយ៉ាងតិចបំផុតបីឆ្នាំ (៣ឆ្នាំ) ហើយមានបញ្ជាក់ក្នុងជីវប្រវត្តិរបស់សមាជិកនោះ។

- ប្រសិនបើនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ គឺជាអង្គភាពដែលបានបង្កើតរួចហើយ ត្រូវផ្តល់មកជាមួយនូវការអធិប្បាយអំពីមុខរបររបស់ខ្លួនព្រមទាំងតារាងតុល្យការ ដែលមានការបញ្ជាក់ ពីស្នងការគណនីសម្រាប់ប្រតិបត្តិការក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ចុងក្រោយ។
- ការពិពណ៌នាពីផែនការសកម្មភាពអាជីវកម្មរយៈពេលបីឆ្នាំ (៣ឆ្នាំ)ទៅមុខ
  - ទំហំនៃការឱ្យខ្ចីគ្រប់ប្រភេទដែលអាចមាននៅក្នុងឬក្រៅតារាងតុល្យការនិងសេវាផ្សេងៗទៀតដែលត្រូវផ្តល់ឱ្យអតិថិជនឬសមាជិក(ចំពោះឥណទាន ប្រភេទ ទម្រង់ គោលបំណង ខ្លឹមសារ និងល័ក្ខខណ្ឌចំបងៗ ផលកំរៃដែលទទួលបានប្រចាំឆ្នាំនិងទឹកប្រាក់មិនទាន់សង)
  - ប្រភេទនិងទំហំនៃសេវាផ្សេងទៀតដែលផ្តល់ឱ្យអតិថិជន (គណនីសន្សំ ការផ្តល់មធ្យោបាយ ទូទាត់ ការគ្រប់គ្រងទ្រព្យសកម្មជាដើម)
  - ប្រភេទអតិថិជន (ឯកជន ឯកត្តជន ក្រុមហ៊ុន អង្គការអន្តរជាតិ វិនិយោគិនជាស្ថាប័ន) ដែលធនាគារមានបំណងប្រាស្រ័យទាក់ទង
  - ប្រភពធនធានហិរញ្ញវត្ថុដែលបានគ្រោងទុក មូលនិធិផ្ទាល់បុរេប្រទានរបស់ភាគទុនិកៈ មូលប័ត្រឥណទេយ្យដែលអាចជួញដូរបាន ប្រាក់បញ្ញើពីសាធារណជនទូទៅ ប្រាក់កម្ចីលើ ទីផ្សារអន្តរធនាគារជាដើមចំនួនប៉ាន់ស្មាននៃនិយោជិតក្នុងរយៈពេលបីឆ្នាំ(៣ឆ្នាំ)ខាងមុខ និងបញ្ជីបើកបៀវត្ស ដោយរាយលំអិតតាមប្រភេទបុគ្គលិក
  - ការចាត់តាំង និងធនធាន ដែលបានគ្រោងទុក ពិសេសចំពោះការទាក់ទងអតិថិជន (ការបង្កើតសាខា) និងចំពោះទម្រង់ការគណនេយ្យនិងឧបករណ៍កុំព្យូទ័រ
  - តារាងតុល្យការ និងការព្យាករណ៍គណនីចំណេញ-ខាតសម្រាប់ការិយបរិច្ឆេទគណនេយ្យបីឆ្នាំ(៣ឆ្នាំ)

ខាងមុខ ត្រូវព្យាករណ៍កំរិតអនុបាតប្រុងប្រយ័ត្នចំបង (ដូចបានកំណត់ដោយ ធនាគារជាតិនៃកម្ពុជា) នៅខាងចុងការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ) ខាងមុខ

- ការត្រួតពិនិត្យផ្ទៃក្នុង៖
  - ការចាត់តាំងផែនការត្រួតពិនិត្យបញ្ជីផ្ទៃក្នុងដែលមានចែងក្នុងមាត្រា ៤៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
  - របៀបកំណត់កំរិតផ្ទៃក្នុងទៅលើប្រភេទហានិភ័យអនុវត្តន៍ឱ្យបានត្រឹមត្រូវនិងទម្រង់ការផ្សេងៗសម្រាប់ធានាការ
  - នីតិវិធីដែលបានគ្រោងទុកសម្រាប់ធានាការអនុវត្តន៍ឱ្យបានត្រឹមត្រូវតាមសីលធម៌វិជ្ជាជីវៈពិសេសចំពោះប្រតិបត្តិការហិរញ្ញវត្ថុជាមួយអតិថិជន និងសម្រាប់រួមចំណែកក្នុងការប្រយុទ្ធប្រឆាំងការសំអាតប្រាក់
  - សមាសភាព និងភារកិច្ចរបស់គណកម្មការត្រួតពិនិត្យបញ្ជី
- ការត្រួតពិនិត្យពីខាងក្រៅ
  - អត្តសញ្ញាណរបស់ស្នងការគណនីឯករាជ្យដែលត្រូវបានជ្រើសរើសពីបញ្ជីប្រតិស្រុតិ

- ប្រភេទនៃមុខងារដែលត្រូវប្រគល់ឱ្យស្នងការគណនីឯករាជ្យនោះ

- ត្រួតពិនិត្យរបស់ទីស្នាក់ការកណ្ដាល ឬក្រុមហ៊ុនដើម (សម្រាប់សាខាធនាគារបរទេស ឬបុត្តសម្ព័ន្ធរបស់ក្រុមហ៊ុនបរទេស)
  - ពិពណ៌នាពីទម្រង់ការសម្រាប់ការត្រួតពិនិត្យសាខាឬបុត្តសម្ព័ន្ធរបស់ក្រុមហ៊ុនដើម
  - ពិពណ៌នាពីការត្រួតពិនិត្យសាខា ឬបុត្រសម្ព័ន្ធបរទេសរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើម។ ភាគទុនិកៈដែលកាន់កាប់ប្រាំភាគយ(៥%)ឬលើសពីនេះនដើមទុន ឬនៃសិទ្ធិបោះឆ្នោតរបស់អ្នកដាក់ពាក្យសុំត្រូវផ្ដល់ព័ត៌មានដូចតទៅ ៖

- អត្តសញ្ញាណរបស់ភាគទុនិកៈ ៖ក្នុងករណីជានីតិបុគ្គល ត្រូវផ្ដល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋាន ទីស្នាក់ ការកណ្ដាលនិងលក្ខន្តិកៈ។ ក្នុងករណីជាឯកត្តជន ត្រូវរៀបរាប់នាម គោត្តនាម ថ្ងៃខែឆ្នាំនិង ទីកន្លែងកំណើត សញ្ជាតិ និងលំនៅដ្ឋាន។ ត្រូវបញ្ជាក់ថា តើបុគ្គលនេះត្រូវបានតែងតាំង ជាអ្នកចាត់ការមួយរូបរបស់ធនាគារឬទេ។ ត្រូវប្រាប់ថា តើភាគទុនិកៈជាសមាជិកនៃក្រុម ប្រឹក្សាភិបាលរបស់គ្រឹះស្ថានឬទេ។ បើមែនត្រូវជានាថាសមាជិកនោះមិនមានពាក់ព័ន្ធជាមួយ ការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទេ។ សម្រាប់គោលបំណងទាំងអស់នេះ បុគ្គលពាក់ព័ន្ធម្នាក់ៗ ត្រូវបំពេញជីវប្រវត្តិ និងសំនួរដូច មានក្នុងឧបសម្ព័ន្ធទី៤
- បញ្ជាក់ពីចំនួននិងភាគរយនៃភាគកម្មដែលបានស្មើនឹងចំនួននិងភាគរយនៃសិទ្ធិបោះឆ្នោត។ រៀបរាប់លំអិតពីការសំរបសំរួលខាងតតិយុត្តិនិងខាងហិរញ្ញវត្ថុចំពោះការទទួលយកមូលប័ត្រ។ បើភាគទុនិកៈជាឯកត្តជន ត្រូវបញ្ជាក់ច្បាស់ពីប្រភពដើមនៃដើមទុនវិនិយោគ។ បង្ហាញថាតើសកម្មភាព ដែលអនុវត្តចំពោះការវិនិយោគបរទេសនៅប្រតិបត្តិការស្ថិតនៅក្រោមចំណុះនីតិវិធីដោយឡែក កម្ពុជាឬទេហើយ តើទម្រង់បែបបទទាំងនេះត្រូវបានបំពេញហើយឬនៅ
- បញ្ជាក់ពីការបែងចែកភាគហ៊ុនរបស់ភាគទុនិកៈ។ បើចាំបាច់ ត្រូវរៀបរាប់ពីការបែងចែក ភាគហ៊ុនរបស់ក្រុមហ៊ុនដើមនិងរបស់ក្រុមហ៊ុនហូលឌីងជាកណ្ដាល ( Intermediation holding companies ) បង្ហាញនូវសមាមាត្រភាគហ៊ុននិងសិទ្ធិបោះឆ្នោត។ ត្រូវរៀបចំបញ្ជីឈ្មោះអ្នកចាត់ការ ធំៗនៃអ្នកចូលហ៊ុន
- រៀបរាប់ពីសកម្មភាពរបស់ភាគទុនិកៈ។ ប្រសិនបើភាគទុនិកៈជាសមាជិកនៃក្រុមមួយត្រូវពិពណ៌នាពីអង្គភាពធំៗនៃក្រុមនោះ រួមជាមួយអង្គការលេខផង។ ត្រូវបញ្ជាក់ផងថាតើភាគទុនិកៈមានទ្រព្យ សម្បត្តិច្រើននៅក្នុងស្ថាប័នឥណទានផ្សេងៗទៀតឬទេបញ្ជាក់ថាតើក្រុមណាដែលជាកម្មសិទ្ធិផ្ទាល់ របស់ភាគទុនិកៈមានទុនច្រើននៅក្នុងគ្រឹះស្ថានឥណទាន ឬទេ? បើមានត្រូវរៀបរាប់ឱ្យអស់។
- ប្រាប់ថាតើភាគទុនិកៈនិងក្រុមហ៊ុនដែលអាចបញ្ចូលជាមួយគ្នាមានធ្វើសកម្មភាពហិរញ្ញវត្ថុឬទេ។ បើមាន ត្រូវបញ្ជាក់ថាក្រុមហ៊ុនទាំងនោះស្ថិតក្រោមចំណុះបទបញ្ជាណា ឬ អាជ្ញាធរណា
- បញ្ជាក់ពីបែបបទនៃការត្រួតពិនិត្យផ្ទៃក្នុងនិងពីខាងក្រៅរបស់ភាគទុនិកៈ
- បញ្ជាក់ថា រតើក្នុងរយៈពេលដប់ឆ្នាំ ( ១០ឆ្នាំ ) កន្លងមក ភាគទុនិកៈបានទទួលរងនូវការស៊ើប អង្កេតឬទទួលរងនូវការពិន័យជាសំភារៈតាមទម្រង់ការវិជ្ជាជីវៈរដ្ឋបាលឬតុលាការនៅកម្ពុជាឬនៅបរទេសឬទេ។ ត្រូវរៀបរាប់ថា តើមានបានទទួលទណ្ឌកម្មណាមួយ ដោយសារការស៊ើបអង្កេតដែរឬទេ ។ បញ្ជាក់ដែរថា

តើភាគទុនិកៈជាកម្មវត្ថុ ឬអាចជាកម្មវត្ថុនៃទម្រង់ការរដ្ឋបាល យុត្តិធម៌ ឬជាមិត្តភាពនៅកម្ពុជាឬនៅបរទេសដែលអាចមានឥទ្ធិពលខាងសំភារៈទៅលើស្ថានភាព ហិរញ្ញវត្ថុរបស់ភាគទុនិកៈ នេះឬទេ។

- ប្រាប់ពីគោលដៅរបស់ភាគទុនិកៈ ក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងធនាគារ ដែលបាន ដាក់ពាក្យសុំអាជ្ញាប័ណ្ណនិងផ្តល់ព័ត៌មានដែលពាក់ព័ន្ធទាំងអស់
- បញ្ជាក់ថា តើមានទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិកៈ និង អ្នកដាក់ពាក្យសុំឬទេហើយតើទំនាក់ទំនងទាំងនេះនឹងត្រូវបានពង្រីកទៅអនាគតយ៉ាងណា
- បញ្ជាក់ថាតើទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងធនាគាររបស់ភាគទុនិកៈនៅកម្ពុជាមានអ្វីខ្លះ ហើយទំនាក់ទំនងទាំងនេះនៅមានរហូតដល់ពេលណាទៀត
- ផ្តល់គណនីនានារបស់ភាគទុនិកៈឬក្រុមហ៊ុនដើមរបស់ខ្លួន សម្រាប់រយៈពេលបីឆ្នាំ (៣ឆ្នាំ) ចុងក្រោយព្រមទាំងធ្វើការព្យាករណ៍សម្រាប់ឆ្នាំនេះ (រួមមានទាំងព័ត៌មានច្របាច់បញ្ចូលគ្នាផង បើចាំ បាច់)។ បើភាគទុនិកៈជាគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវផ្តល់ព័ត៌មានពីអនុបាតប្រុងប្រយ័ត្នសំខាន់ៗ។
- ប្រការ ៦ .-

បុគ្គលម្នាក់ក្នុងចំណោមពីររូប (២រូប) ដែលត្រូវបានតែងតាំងក្នុងមុខតំណែងគ្រប់គ្រង ដូចជាការទទួលខុសត្រូវក្នុងការដឹកនាំអាជីវកម្មធនាគារឱ្យមានប្រសិទ្ធភាពត្រូវផ្តល់ព័ត៌មានដូចខាងក្រោមនេះ(២) ដោយបំពេញជីវប្រវត្តិ និងសំនួរដូចមានក្នុងឧបសម្ព័ន្ធទី៤

- អត្តសញ្ញាណរបស់នាយកចាត់ការៈ
    - នាម និងគោត្តនាម
    - ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត សញ្ជាតិ
    - អាសយដ្ឋានផ្ទាល់ខ្លួន (ត្រូវមានទីកន្លែងស្នាក់នៅក្រោយពេលបានទទួលការតែងតាំង បើមានការផ្លាស់ប្តូរ។ នាយកចាត់ការត្រូវមានកន្លែងស្នាក់នៅជិតកន្លែង សំខាន់សម្រាប់ធ្វើអាជីវកម្ម ដូចជានៅក្នុងប្រទេសកម្ពុជា)
- គុណវុឌ្ឍិ និងបទពិសោធន៍ ៖
    - សញ្ញាប័ត្រ ក៏ដូចជាថ្ងៃខែឆ្នាំនិងកន្លែងទទួលសញ្ញាប័ត្រ
    - មុខតំណែងដែលបានកាន់កាប់ក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ)ចុងក្រោយ ដោយមាន ឈ្មោះ

ទីកន្លែង និងសកម្មភាពរបស់និយោជក ប្រភេទបទពិសោធន៍ទទួលបាននិង កំរិតទទួលខុសត្រូវ។

- បញ្ជាក់ថា តើក្នុងការអនុវត្តន៍ភារកិច្ចរបស់ខ្លួន នាយកចាត់ការនឹងចូលរួមសហការ ឬ មានការ ព្រមព្រៀងជាមួយគ្រឹះស្ថានជាឯកត្តជនឬជានីតិបុគ្គលមួយផ្សេងទៀតក្រៅពីអ្នកដាក់ ពាក្យសុំឬទេ។ ក្នុងករណីណាមួយ ក៏ត្រូវផ្តល់ព័ត៌មានទាំងអស់ដែលពាក់ព័ន្ធ។
- រៀបរាប់ពីភារកិច្ចគ្រប់គ្រង ដែលនាយកចាត់ការទទួលខុសត្រូវដោយផ្ទាល់។
- បញ្ជាក់ថា តើនាយកចាត់ការនៅជាឬធ្លាប់បានធ្វើជាភាគទុនិកៈសំខាន់(ដូចជាបានកាន់កាប់ភាគហ៊ុនដោយផ្ទាល់ ឬដោយប្រយោលយ៉ាងតិចបំផុតដប់ភាគរយ (១០%) នៃដើមទុនឬ នៃសិទ្ធិបោះឆ្នោត)នៃក្រុមហ៊ុនណាមួយក្រៅពីអ្នកដាក់ពាក្យស្នើសុំឬទេប្រសិនបើមានត្រូវប្រាប់ឈ្មោះនិងសកម្មភាពរបស់ក្រុមហ៊ុនចំនួនប្រាក់ និងភាគហ៊ុនរបស់ខ្លួនឬផលប្រយោជន៍ក្នុងក្រុមហ៊ុននោះ។

- ប្រាប់តាមការយល់ដឹងរបស់ខ្លួនថា តើក្រុមហ៊ុនណាខ្លះដែលខ្លួនបានកាន់កាប់តំណែងជាអ្នកទទួលខុសត្រូវឬក្នុងក្រុមហ៊ុនណាដែលខ្លួនជាភាគទុនិកៈសំខាន់ដែលខ្លួនមានទំនាក់ទំនងអាជីវកម្មសំខាន់ជាមួយអ្នកស្នើសុំ។
- បញ្ជាក់ថា រតើនៅកម្ពុជា ឬនៅបរទេស ខ្លួនធ្លាប់បានទទួលរងនូវទណ្ឌកម្មតាមនីតិវិធីរដ្ឋ ជីវៈរដ្ឋបាល ឬតុលាការឬទេ។ ត្រូវរាយល់អិតនូវព័ត៌មានទាំងអស់ឱ្យបានសមស្រប។
- បញ្ជាក់ថា តើខ្លួនធ្លាប់បានទទួលរងនូវវិន័យ ឬការបណ្តេញពីនិយោជកណាមួយដែរឬ ទេ។ បើមានត្រូវរាយលំអិតនូវព័ត៌មាន ដែលពាក់ព័ន្ធទាំងអស់។
- បញ្ជាក់ថា តើខ្លួនជាអ្នកផ្តល់ដើមទុនទៅឱ្យអ្នកស្នើសុំឬទេ ហើយតើខ្លួនមានបំណង អនុវត្ត ដោយផ្ទាល់ឬតាមរយៈអន្តរការី នូវសកម្មភាពប្រតិបត្តិការឯកត្តជនឬរដ្ឋជីវៈជាមួយ អ្នកស្នើសុំឬទេ។
- ផ្តល់ព័ត៌មានបន្ថែមទាំងអស់ដែលអាចជួយបំភ្លឺដល់ធនាគារជាតិនៃកម្ពុជា។

រាល់ចម្លើយទាំងអស់ដែលទាក់ទងទៅនឹងសំនួរខាងលើ ត្រូវផ្ញើជូនតាមរយៈជីវប្រវត្តិ និងសំនួរក្នុងឧបសម្ព័ន្ធទី ៤ និងលិខិតស្របតាមគំរូលិខិតដូចមានក្នុងឧបសម្ព័ន្ធទី ២។ភាគទុនិកៈដែលកាន់កាប់ដោយផ្ទាល់ឬប្រយោល យ៉ាងតិចបំផុតថ្ងៃភាគរយ(២០%) នៃដើមទុន ឬនៃសិទ្ធិបោះឆ្នោត ត្រូវបានចាត់ទុកថាជាភាគទុនិកៈមានឥទ្ធិពល ស្របតាមមាត្រា ២៦ នៃច្បាប់ស្តីពី គ្រឹះ ស្ថានធនាគារនិងហិរញ្ញវត្ថុ។ ភាគទុនិកៈមានឥទ្ធិពលត្រូវបានធនាគារជាតិនៃកម្ពុជាតម្រូវឱ្យបង្កើនមូលនិធិ ផ្ទាល់សុទ្ធរបស់ធនាគារ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុ។ សម្រាប់គោលបំណងនោះ ត្រូវផ្ញើលិខិតដូចមានគំរូនៅក្នុងឧបសម្ព័ន្ធ ទី៣ ទៅទេសាភិបាល ធនាគារជាតិ នៃកម្ពុជា។បទបញ្ញានេះអាចត្រូវដកចេញវិញបានតែនៅពេលមានការបង្កើតឱ្យមានការធានារ៉ាប់រងលើប្រាក់បញ្ញើនៅកម្ពុជា[10]។

### ២.២.៤ យុទ្ធសាស្ត្រក្នុងការរៀបចំឥណទានឡើងវិញរបស់ធនាគារ

យុទ្ធសាស្ត្រនៅក្នុងការរៀបចំឥណទានឡើងវិញ (Loan Restructuring Strategy) របស់ធនាគារមានគោលបំណងជួយអោយអតិថិជនដែលជួបការលំបាកក្នុងការទូទាត់បំណុលអាចបន្តបំពេញបំណុលរបស់ខ្លួនបាន និងបញ្ចៀសការបាត់បង់បំណុលឬការលែងសងទាំងស្រុង។ យុទ្ធសាស្ត្រនេះត្រូវបានអនុវត្តតាមបែបរដ្ឋជីវៈនិងប្រកាន់លក្ខខណ្ឌដែលធនាគារអាចទទួលយកបាន។ វាអាចមានដំណើរការដូចខាងក្រោម៖

១. វាយតម្លៃស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន

- ធនាគារត្រួតពិនិត្យលើលទ្ធភាពសងប្រាក់របស់អតិថិជន (cash flow, source of income)
- បញ្ជាក់ពីមូលហេតុដែលបង្កឲ្យមានការលំបាកក្នុងការសង។

២. កំណត់ជម្រើសនៃការរៀបចំឡើងវិញ

- ធនាគារអាចអនុវត្តវិធីសាស្ត្រច្រើន ដើម្បីធ្វើឥណទានឡើងវិញ ដូចជា៖
    - បន្ថយអត្រាការប្រាក់
    - ពន្យារពេលសង (loan tenor extension)

[10]ធនាគារជាតិនៃកម្ពុជា. (២០២៤). *ទ្រឹស្តីពាក់ព័ន្ធ?* Retrieved from https://www.nbc.gov.kh/download_files/legislation/prakas_kh/1031b7-00-04.pdf ទំព័រ ៣៧៧-៣៨១

- បញ្ឈប់ការទូទាត់ផ្នែកដើមរយៈពេលខ្លះ (grace period)
- បង្វិលការបំណុល (loan rescheduling or restructuring)
- ប្តូរពីឥណទានខ្លីទៅឥណទានវែង
- បន្ថយឬលុបចោលទំនាក់ទំនងនៃការថយបង់ (penalty or late fees)

៣. ចុះហត្ថលេខាលើកិច្ចសន្យាថ្មី

- បន្ទាប់ពីឯកភាពលើលក្ខខណ្ឌថ្មី ធនាគារ និងអតិថិជនត្រូវចុះហត្ថលេខាលើកិច្ចសន្យាថ្មីនៃការសងប្រាក់។

៤. តាមដាននិងវាយតម្លៃបន្ត

- ធនាគារត្រូវបន្តតាមដានការសងប្រាក់ក្រោយពេលរៀបចំឥណទានឡើងវិញ។
- ប្រសិនបើអតិថិជននៅតែជួបបញ្ហា ដូច្នេះអាចត្រូវពិចារណាជម្រើសបន្ថែម ឬវិធានការផ្សេងៗ។

➢ គោលបំណងសំខាន់របស់យុទ្ធសាស្ត្រនេះ

- ជួយអោយអតិថិជនសងប្រាក់បានតាមសមត្ថភាព។
- កាត់បន្ថយការបាត់បង់ឥណទាន (non-performing loan - NPL) របស់ធនាគារ។
- រក្សាទំនាក់ទំនងល្អជាដៃគូរវាងអតិថិជននិងធនាគារ។

## ២.៣.លក្ខណៈទូទៅនៃការរៀបចំឲឥណទានឡើងវិញ

### ២.៣.១.និយមន័យការរៀបចំឥណទានឡើងវិញ

ការរៀបចំឥណទានឡើងវិញ (Loan-Restructuring) គឺជាដំណើរការកែសម្រួលលក្ខខណ្ឌនៃកម្ចីដើម ដើម្បីជួយឲ្យអតិថិជនមានសមត្ថភាពបង់ប្រាក់បន្តដោយផ្លាស់ប្តូរជាផ្លូវការតាមការព្រមព្រៀងរវាងអតិថិជន និង ស្ថាប័នហិរញ្ញវត្ថុ។

### ២.៣.២.ប្រវត្តិនៃការរៀបចំឥណទានឡើងវិញ

មានប្រវត្តិជាយូរឆ្នាំដែលទាក់ទងទៅនឹងការអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុនិងការចរចាររវាងអ្នកផ្តល់ឥណទាន និងអ្នកខ្ចីប្រាក់។វាបានក្លាយជាមធ្យោបាយសំខាន់សម្រាប់ការប្រយុទ្ធនឹងវិបត្តិហិរញ្ញវត្ថុនិងការចាញ់បោកនៃស្ថាប័ន ហិរញ្ញវត្ថុ។

❖ សតវត្សទី 21 - វិបត្តិហិរញ្ញវត្ថុឆ្នាំ 2008 និង COVID-វិបត្តិហិរញ្ញវត្ថុពិភពលោក (2008-2009) ការ បាញ់ចូលថវិកាជួយសង្គ្រោះ (bailouts19) និងការរៀបចំឥណទានឡើងវិញចំពោះអតិថិជនដែល មានបំណុលខ្ពស់។តំបន់អឺរ៉ុបនិងអាមេរិកបានអនុវត្តការតាមដានបំណុលយ៉ាងតឹងរឹង។ COVID-19 (2019-2021)ប្រទេសជាច្រើនបានអនុវត្តការលើកលែងការបង់ប្រាក់ជាបណ្តោះអាសន្ន និងបន្ថែមរយៈ ពេលបង់ប្រាក់សម្រាប់អតិថិជន។ស្ថាប័នហិរញ្ញវត្ថុច្រើនបានកែសម្រួលនយោបាយបំណុលដើម្បីជួយ សហគ្រាស និងបុគ្គល។នីតិសម្បទានសម្រាប់អនាគតការរៀបចំឥណទានឡើងវិញកំពុងក្លាយជា ផ្នែកសំខាន់នៃគោលនយោបាយហិរញ្ញវត្ថុ។បច្ចេកវិទ្យា និងធនាគារឌីជីថលកំពុងជួយឲ្យការរៀបចំ ឡើងវិញមានប្រសិទ្ធភាព និងបើកទូលាយជាងមុន។អង្គការហិរញ្ញវត្ថុអន្តរជាតិដូចជា IMF និង World Bank បន្តជួយឲ្យប្រទេសក្រីក្រមានការរៀបចំឥណទានឡើងវិញដោយប្រើឧបត្ថម្ភបន្ថែម។

សរុបមក៖ ការរៀបចំឥណទានឡើងវិញ មានប្រវត្តិយូរឆ្នាំដែលពាក់ព័ន្ធនឹងវិបត្តិហិរញ្ញវត្ថុ និងការ ផ្លាស់ប្តូរគោលនយោបាយហិរញ្ញវត្ថុនៅលើពិភពលោក។

**២.៣.៣.ទ្រឹស្តីនៃការរៀបចំឥណទានឡើងវិញ**

ការរៀបចំឥណទានឡើងវិញមានន័យថាគឺជាឥណទានដែលត្រូវបានធ្វើការកែប្រែកាលកំណត់សងឬធ្វើហិរញ្ញប្បទានឡើងវិញស្របទៅតាមកិច្ចសន្យាដែលកំណត់ការទូទាត់សងទៅតាមគ្រាថ្មីដោយសារភាពទន់ខ្សោយនៅស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុលឬកង្វះលទ្ធភាពនៅក្នុងការទូទាត់សងឥណទានដូចដែលបានព្រមព្រៀងពីដំបូង។

ការរៀបចំឥណទានឡើងវិញអាចត្រូវបានធ្វើចំពោះតែអ្នកខ្ចីណាដែលមានដំណើរការអាជីវកម្ម ល្អនាពេលខាងមុខ ហើយដែលកំពុងជួប ឬ រំពឹងថាជួបការលំបាកជាបណ្តោះអាសន្នក្នុងការសងត្រឡប់ វិញនូវប្រាក់ដើម និងឬ ការប្រាក់ ។

គ្រឹះស្ថានត្រូវបានហាមឃាត់អនុវត្តការរៀបចំបំណុលឡើងវិញ ដោយគ្រាន់តែក្នុងគោលបំណងជៀសវាង៖

- ការធ្លាក់ចំណាត់ថ្នាក់របស់ខ្លួនព្រោះតែចំណាត់ថ្នាក់ឥណទាន
- ការកើនឡើងនូវសំវិធានធនលើឥណទានបាត់បង់
- បញ្ឈប់ការទទួលស្គាល់ចំណូលការប្រាក់លើមូលដ្ឋានបង្គរ ។

ឥណទានដែលនឹងត្រូវរៀបចំឡើងវិញ ត្រូវវិភាគលើមូលដ្ឋានទិសដៅអាជីវកម្ម និងសមត្ថភាព សងប្រាក់វិញរបស់អ្នកខ្ចីទៅតាមការព្យាករណ៍លំហូរសាច់ប្រាក់ថ្មី ដែលស្របតាមស្ថានភាពទីផ្សារ និង បច្ចុប្បន្នកម្មនៃទស្សនៈវិស័យអាជីវកម្ម ដោពារផ្អែកលើសម្មតិកម្មជាក់ស្តែងនិងប្រុងប្រយ័ត្ន។

ការរៀបចំឡើងវិញនៃឥណទាន ត្រូវធ្វើឡើងដោយក្រុមការងារមួយដែលត្រូវតែនៅដាច់ដោយឡែកពីក្រុមដែលទទួលខុសត្រូវលើដំណើរការឱ្យខ្ចី។ ក្នុងករណីដែលការចូលរួមរបស់ភ្នាក់ងារ ឬ បុគ្គលិកនៅក្នុងក្រុមដំណើរការឱ្យខ្ចីនេះមិនអាចជៀសបាននោះ ក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានត្រូវតាម ដានផ្ទាល់ឱ្យបានតឹងតែងលើការរៀបចំឡើងវិញនៃឥណទាន ។

បន្ទាប់ពីឥណទានត្រូវបានរៀបចំឡើងវិញ គ្រឹះស្ថានត្រូវចាត់ថ្នាក់ឥណទាននោះដូចខាងក្រោម៖

- មិនល្អជាងក្រោមស្តង់ដារ សម្រាប់ឥណទានដែលពីមុនមកត្រូវបានចាត់ថ្នាក់ជា សង្ស័យ ឬបាត់បង់
- មិនផ្លាស់ប្តូរសម្រាប់ឥណទានដែលពីមុនមក ត្រូវបានចាត់ថ្នាក់ជាឥណទានធម្មតា ឃ្លាំមើល ឬ ក្រោមស្តង់ដារ ។
- ការចាត់ថ្នាក់នេះ មិនត្រូវបានល្អជាងមុនឡើយ លុះត្រាតែការប្រាក់នឹងប្រាក់ដើមត្រូវបានសងមកវិញ ក្នុងអំឡុងបង់រំលស់បីលើកជាប់គ្នា និងក្នុងរយៈពេលមិនតិចជាងបីខែ។ បន្ទាប់ពីរយៈពេលនេះ ឥណទាន ដែលត្រូវបានរៀបចំឡើងវិញអាចត្រូវបានចាត់ថ្នាក់ទៅតាមប្រការ ៤ នៃប្រកាសនេះ[11]។

**២.៣.៤ លក្ខខណ្ឌនៃការរៀបចំឥណទានឡើងវិញ**

ក្នុងគោលបំណងជួយសម្រាលបន្ទុកចំណាយប្រចាំគ្រារបស់អតិថិជនក្នុងការបំពេញកាតព្វកិច្ចសងត្រឡប់ឥណទាន និងជំរុញកំណើនសេដ្ឋកិច្ចតាមរយៈការបង្កើនលំហូរសាច់ប្រាក់ ធនាគារជាតិនៃកម្ពុជា

[11] ធនាគារជាតិនៃកម្ពុជា. (២០២៤). *ទ្រឹស្តីនៃការរៀបចំឥណទានឡើងវិញ?* Retrieved from https://www.nbc.gov.kh/download_files/legislation/prakas_kh/1031b7-00-04.pdf ទំព័រ ៤

អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា "គ្រឹះស្ថាន" រៀបចំឥណទានឡើងវិញជូន អតិថិជន ដោយត្រូវអនុវត្តលក្ខខណ្ឌដូចខាងក្រោម៖

- គ្រឹះស្ថានអាចរៀបចំឥណទានឡើងវិញជូនអតិថិជនបានចំនួន ២ (ពីរ) ដង ដោយអាចរក្សា ចំណាត់ថ្នាក់ដដែល និងមិនចាំបាច់ធ្វើសំវិធានធនបន្ថែម។
- គ្រឹះស្ថានអាចអនុវត្តការដំឡើងចំណាត់ថ្នាក់ឥណទានរៀបចំឡើងវិញក្នុងអំឡុងពេលអនុគ្រោះ នេះ លើកដំបូងពីមួយកម្រិតទៅមួយកម្រិត បន្ទាប់ពីអតិថិជនបានបំពេញកាតព្វកិច្ចទូទាត់សង បន្តបន្ទាប់គ្នា ក្នុងរយៈពេលយ៉ាងតិច ៣ (បី) ខែ ចំពោះឥណទានដែលមានការទូទាត់សង ប្រាក់ដើម និង/ឬ ការប្រាក់ ប្រចាំខែ។ បន្ទាប់មក គ្រឹះស្ថានអាចស្តារចំណាត់ថ្នាក់ឥណទានល្អ ជាងមុនពីមួយកម្រិតទៅមួយកម្រិត ទៀត ដោយគោរពតាមគោលការណ៍ចំនួនថ្ងៃហួសកាល កំណត់សងនៃការទម្លាក់ចំណាត់ថ្នាក់ឥណទាន។ លើសពីនេះ ការដំឡើងចំណាត់ថ្នាក់ត្រូវគោរព តាមលក្ខខណ្ឌដូចខាងក្រោម៖
  - ចំពោះឥណទានមិនដំណើរការដែលមិនធ្លាប់ត្រូវបានរៀបចំឡើងវិញ (លើកលែងឥណទាន រៀបចំឡើងវិញក្នុងអំឡុងពេលអនុគ្រោះកន្លងមក) ហើយបានស្នើសុំការរៀបចំឡើងវិញ ក្នុងអំឡុងពេល អនុគ្រោះនេះ ការដំឡើងចំណាត់ថ្នាក់អាចធ្វើពីមួយកម្រិតទៅមួយកម្រិត រហូតដល់ចំណាត់ថ្នាក់ "ស្តង់ដា"
  - ចំពោះឥណទានដំណើរការដែលធ្លាប់ត្រូវបានរៀបចំឡើងវិញមួយលើក (លើកលែង គណទាន រៀបចំឡើងវិញក្នុងអំឡុងពេលអនុគ្រោះកន្លងមក) ហើយក្លាយជាឥណទាន មិនដំណើរការ និង បានស្នើសុំការរៀបចំឡើងវិញក្នុងអំឡុងពេលអនុគ្រោះនេះ ការដំឡើង ចំណាត់ថ្នាក់អាចធ្វើពីមួយកម្រិតទៅមួយកម្រិតរហូតដល់ចំណាត់ថ្នាក់ "ស្តង់ដា"

ចំពោះឥណទានមិនដំណើរការដែលធ្លាប់ត្រូវបានរៀបចំឡើងវិញ (លើកលែងឥណទាន រៀបចំឡើងវិញក្នុងអំឡុងពេលអនុគ្រោះកន្លងមក) ហើយបានស្នើសុំការរៀបចំឡើងវិញក្នុងអំឡុងពេលអនុគ្រោះនេះការដំឡើងចំណាត់ថ្នាក់មិនអាចខ្ពស់ជាង "ក្រោមស្តង់ដា" ទេ។ ការដំឡើងចំណាត់ថ្នាក់នេះ ត្រូវចាប់ផ្តើមអនុវត្តចាប់ពីត្រីមាសទី៤ ឆ្នាំ២០២៤៨ តទៅ។

ទន្ទឹមនេះ ការដំឡើងចំណាត់ថ្នាក់នេះ ក៏ត្រូវបានអនុវត្តចំពោះឥណទានរៀបចំឡើងវិញ ចំពោះវិស័យទេសចរណ៍នៅខេត្តសៀមរាប ដែលបានកំណត់នៅក្នុងសារាចរណែនាំលេខ ធ៧.០២៣.០០១ សារាចរ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ផងដែរ[12]។

### ២.៣.៥ អត្ថប្រយោជន៍នៃការរៀបចំឥណទានឡើងវិញ

#### ក.អត្ថប្រយោជន៍ចំពោះធនាគារ

អត្ថប្រយោជន៍ចំពោះធនាគារមានដូចជា៖

- បន្តទទួលបានប្រាក់បង់វិញ៖ ធនាគារមិនចាំបាច់បាត់បង់ប្រាក់ជាប្រភពប្រាក់ចំណូលទាំងស្រុង។
- បញ្ចៀសពីការបាត់បង់ទ្រព្យបំណុល៖ ជំនួសឲ្យចាត់វិធានការផ្តាច់ដូចជាចាប់យកប្រាក់ជានាការ លក់ដោយគ្មានកិច្ចសន្យា។

[12] ធនាគារជាតិនៃកម្ពុជា. *លក្ខខណ្ឌនៃការរៀបចំឥណទានឡើងវិញ?* Retrieved March, 15 2025 from https://www.nbc.gov.kh/download_files/legislation/prakas_kh/B7-024-001_C.L_Circular_on_LoanRestructuring_20240829.pdf ទំព័រ ១-៣

- រក្សាភាពជាដៃគូជាទីទុកចិត្តៈ ជួយរក្សាទំនាក់ទំនងល្អជាមួយអតិថិជន ហើយអាចនាំឲ្យមានអាជីវកម្មបន្ថែម។
- បង្ការ Non-Performing Loans (NPL)៖ ជួយកាត់បន្ថយអត្រាបំណុលអតិថិជនដែលបាត់បង់សមត្ថភាពបង់វិញ។

### ខ. អត្ថប្រយោជន៍ចំពោះអតិថិជន

អត្ថប្រយោជន៍ចំពោះអតិថិជនមានដូចជា៖

- បន្ថយបន្ទុកហិរញ្ញវត្ថុ៖ ជាពិសេសនៅពេលជួបបញ្ហាហិរញ្ញវត្ថុ អតិថិជនអាចបន្តបង់ប្រាក់ដោយមិនមានបន្ទុកខ្លាំងបាត់បង់ចំណូល។
- ជួយពន្យារពេលនៅក្នុងការបង់សងត្រឡប់
- ជួយសម្រួលការប្រាក់និងបន្ធូរបន្ថយការប្រាក់
- ជួយសម្រួលបន្ទុកដល់អតិថិជនដោយការផ្អាកសងត្រឡប់ជាបណ្តោះអាសន្ន រឺបង់តែការប្រាក់សិន ហើយប្រាក់ដើមនិងសងត្រឡប់នៅពេលក្រោយ
- អាចស្នើសុំគ្រឹះស្ថានហិរញ្ញវត្ថុពន្យារពេលបង់សងប្រាក់ដើមរឺការប្រាក់ក្នុងកំឡុងពេលជាក់លាក់ណាមួយ
- បញ្ចៀសពីការខូចឥរិយាបថឥណទាន(CBC)៖ការរៀបចំឡើងវិញអាចជួយអោយអតិថិជនរក្សាឥរិយាបថឥណទានល្អ។
- បន្តការប្រើប្រាស់ទ្រព្យសម្បត្តិ៖ ដូចជាផ្ទះ ឬរថយន្ត ដោយមិនបាត់បង់វា។
- មានពេលសម្រាប់ស្តារស្ថានភាពហិរញ្ញវត្ថុ៖ បង្កើនឱកាសស្តារការលូតលាស់ផ្នែកហិរញ្ញវត្ថុវិញ។

# ជំពូកទី៣
# ផលប្រយោជន៍នៃការរៀបចំឥណទានឡើងវិញរបស់ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក

## ៣.១ ស្ថានភាពទូទៅនៃធនាគារ ស៊ិនហាន

### ៣.១.១ ប្រវត្តិរបស់ធនាគារ ស៊ិនហាន

ធនាគារ ស៊ិនហាន(ខេមបូឌា) ម.ក ត្រូវបានបង្កើតឡើងនៅទីក្រុងភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា តាំងពីខែតុលា ឆ្នាំ២០០៧ (សាខាធនាគារស៊ិនហាន នៃប្រទេសកូរ៉េ)។ ធនាគារផ្តល់ជូននូវផលប័ត្រចម្រុះនៃផលិតផល និងដំណោះស្រាយធនាគារសម្រាប់អតិថិជន និងសាជីវកម្មដែលតម្រូវតាមតម្រូវការ។ ធនាគារស៊ិនហាន បាននឹងកំពុងត្រួសត្រាយអនាគតហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាក្នុងនាមជា "First Mover" នាំមុខគេក្នុងទីផ្សារ ជាជាងធ្វើជា "Fast Follower" ដែលតស៊ូដើម្បីចាប់យកផលិតផល និងបច្ចេកវិទ្យាថ្មីៗ។ ពួកយើងនឹងមិនដែលរីករាយជាមួយនឹងស្ថានភាពបច្ចុប្បន្ននៃពាណិជ្ជកម្មហិរញ្ញវត្ថុ ដែលបច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) កំពុងតែធ្វើអោយមានការធ្លាក់ចុះនៃព្រំដែនសាមញ្ញរបស់សេវាកម្មហិរញ្ញវត្ថុ។ ប៉ុន្តែពួកយើងនឹងបន្តការទទួលស្គាល់នៃការបង្កើតថ្មីៗ ខណៈពេលដែលយើងបានក្រោកឈរប្រឈមនឹងឧបសគ្គដើម្បីផ្តល់ជូននូវ អនាគតកាលនៃសេវាកម្មថ្មីៗ។




រូបភាពទីស្នាក់ការកណ្តាលនៅប្រទេសកម្ពុជា




រូបភាពទីស្នាក់ការកណ្តាលនៅប្រទេសកូរ៉េ

- ឆ្នាំ ២០០៧ ធនាគារស៊ិនហានខ្មែរត្រូវបានបង្កើតឡើងរាជធានីភ្នំពេញព្រះរាជាណាចក្រកម្ពុជា( បុត្រសម្ព័ន្ធរបស់ធនាគារស៊ិនហាន កូរ៉េ)
- ឆ្នាំ ២០១១ បង្កើតសាខា អូឡាំពិកជាសាខាទីមួយនៅរាជធានីភ្នំពេញ
- ឆ្នាំ ២០១២ បង្កើតសាខា ទឹកថ្លាជាសាខាទីពីរ
- ឆ្នាំ ២០១៣ ផ្លាស់ប្តូរសាខាអូឡាំពិកសម្រាប់ការពង្រីកអាជីវកម្ម
- ឆ្នាំ ២០១៥ បង្កើតសាខាដូនពេញ ដែលជាសាខាទីបី
- ឆ្នាំ ២០១៥ បង្កើតសាខាស្ទឹងមានជ័យ ដែលជាសាខាទីបួន
- ឆ្នាំ ២០១៦ ការដាក់ឲ្យប្រើប្រាស់ប័ណ្ណឥណពន្ធវីសា
- ឆ្នាំ ២០១៨ ផ្លាស់ប្តូរទីតាំងរបស់ទីស្នាក់ការកណ្តាលសម្រាប់ការពង្រីកអាជីវកម្ម
- ឆ្នាំ ២០១៨ បង្កើតសាខានរោត្តម ដែលជាសាខាទីប្រាំ
- ឆ្នាំ ២០២០ បង្កើតសាខាទួលគោក ដែលជាសាខាទីប្រាំមួយ
- ឆ្នាំ ២០២០ បង្កើតសាខាសែនសុខ ដែលជាសាខាទីប្រាំពីរ
- ឆ្នាំ ២០២០ បង្កើតសាខាច្បារអំពៅ ដែលជាសាខាទីប្រាំបី
- ឆ្នាំ ២០២០ បង្កើតសាខាបឹងកេងកង ដែលជាសាខាទីប្រាំបួន
- ឆ្នាំ ២០២១ បង្កើតសាខាទួលគោក ដែលជាសាខាទីប្រាំមួយ
- ឆ្នាំ ២០២១ បង្កើតសាខាម៉ៅសេទុង ដែលជាសាខាទីដប់
- ឆ្នាំ ២០២១ បង្កើតសាខាជ្រោយចង្វារ ដែលជាសាខាទីដប់មួយ
- ឆ្នាំ ២០២១ ផ្លាស់ប្តូរទីតាំងរបស់សាខាស្ទឹងមានជ័យ សម្រាប់ការពង្រីកអាជីវកម្ម
- ឆ្នាំ ២០២១ ផ្លាស់ប្តូរទីតាំងរបស់សាខាមុនីវង្ស សម្រាប់ការពង្រីកអាជីវកម្ម
- ឆ្នាំ ២០២១ ផ្លាស់ប្តូរទីតាំងរបស់សាខាទឹកថ្លា សម្រាប់ការពង្រីកអាជីវកម្ម
- ឆ្នាំ ២០២២ បង្កើតសាខាតាខ្មៅ ដែលជាសាខាទីដប់ពីរ
- ឆ្នាំ ២០២២ បង្កើតសាខាសៀមរាប ដែលជាសាខាទីដប់បី
- ឆ្នាំ ២០២៣ បង្កើតសាខាឫស្សីកែវ ដែលជាសាខាទីដប់បួន
- ឆ្នាំ ២០២៣ សាខាចោមចៅ ត្រូវផ្លាស់ប្តូរទីតាំង សម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន

**៣.១.២ ចក្ខុវិស័យ បេសកកម្មរបស់ធនាគាស៊ិនហាន**

**ក.ចក្ខុវិស័យ**

ធ្វើជាធនាគារបុគ្គលិកលំដាប់លើជាសកល ដែលផ្តល់សេវាកម្មហិរញ្ញវត្ថុយ៉ាងឈានមុខ និងមានចំណេះដឹងបំផុតដើម្បីចងសម្ព័ន្ធភាពយូរអង្វែងជាមួយអតិថិជន។

- ធនាគារ ស៊ិនហាន មានគោលដៅក្លាយជាក្រុមហិរញ្ញវត្ថុអន្តរជាតិឈានមុខ ដែលគេគោរព និងទុកចិត្តដោយសារទំនួលខុសត្រូវ និងគុណភាព។
- ផ្តោតលើបច្ចេកវិទ្យាទំនើប និងចំណេះដឹងអាជីវកម្មខ្ពស់ ដើម្បីបង្កើតសេវាដែលមានភាពច្នៃប្រឌិត និងសម័យទំនើប។

- គោលបំណងមិនមែនសំរាប់ការរកចំណេញខ្លីៗទេ ប៉ុន្តែចង់កសាងទំនាក់ទំនងឧត្តមជាមួយអតិថិជនដែលអាចបន្តបានយូរ។

**ខ.បេសកកម្ម**

បេសកកម្មរបស់ធនាគារគឺផ្តល់សេវាហិរញ្ញវត្ថុដែលមានគុណភាពខ្ពស់ និងឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនបុគ្គល និងអាជីវកម្ម។ ធនាគារមានគោលបំណងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាតាមរយៈការគាំទ្រដល់អាជីវកម្មខ្នាតតូច និងមធ្យម (SMEs) និងការផ្តល់ប្រាក់កម្ចីសម្រាប់គម្រោងអភិវឌ្ឍន៍សំខាន់ៗ។ បង្កើតតម្លៃសំខាន់សម្រាប់អតិថិជន បុគ្គលិក អ្នកភាគហ៊ុន និងសង្គមតាមរយៈការផ្តល់សេវាហិរញ្ញវត្ថុដែលមានគុណភាព និងច្នៃប្រឌិត។

- មិនមែនផ្តល់តែសេវាទេ ប៉ុន្តែបង្កើតអត្ថប្រយោជន៍ជាក់ស្តែង និងចាំបាច់សម្រាប់ភាគីទាំងឡាយ។
- មានការយកចិត្តទុកដាក់មិនត្រឹមតែអតិថិជនទេ ប៉ុន្តែរួមទាំងបុគ្គលិកដែលជាចំណុចស្នូល នៃការអភិវឌ្ឍ និងសង្គមទាំងមូលផងដែរ។
- ផ្តោតលើការផ្តល់សេវាដែលមានគុណភាពខ្ពស់ ដោយប្រើបច្ចេកវិទ្យា និងគំនិតថ្មីៗ ដើម្បីបំពេញតម្រូវការអតិថិជន។

**៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់ធនាគារ ស៊ិនហាន**

**ក. រចនាសម្ព័ន្ធគ្រប់គ្រង**

ធនាគារស៊ិនហាន (ខេមបូឌា) ម.ក. មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ និងមានប្រសិទ្ធភាព។ រចនាសម្ព័ន្ធនេះរួមមានក្រុមប្រឹក្សាភិបាលដែលកំណត់ទិសដៅយុទ្ធសាស្ត្រ គណៈគ្រប់គ្រងជាន់ខ្ពស់ដែលគ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃ និងនាយកដ្ឋានផ្សេងៗដែលទទួលខុសត្រូវលើមុខងារជាក់លាក់។



### ខ. តួនាទី និងភារកិច្ចគណៈគ្រប់គ្រង

តួនាទី និងភារកិច្ចរបស់ គណៈគ្រប់គ្រង (Management Team) នៃធនាគារ ស៊ិនហាន (Shinhan Bank) មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការដឹកនាំ និងគ្រប់គ្រងការប្រតិបត្តិរបស់ធនាគារ ដើម្បីធានាបាននូវការអភិវឌ្ឍរយៈពេលវែង និងសមិទ្ធផលសេដ្ឋកិច្ចរបស់ស្ថាប័ន។ ខាងក្រោមនេះជាការបកស្រាយតួនាទី និងភារកិច្ចសំខាន់ៗ៖

១.តួនាទី (Roles) នៃគណៈគ្រប់គ្រងដឹកនាំយុទ្ធសាស្ត្រ

- កំណត់ទិសដៅរយៈពេលខ្លី និងវែងរបស់ធនាគារ
- បង្កើតយុទ្ធសាស្ត្រអភិវឌ្ឍអាជីវកម្ម និងបច្ចេកវិទ្យា

២. គ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃ

- ទស្សនវិស័យត្រូវបានបម្លែងជាទស្សន៍ទាយនិងផែនការ
- គ្រប់គ្រងការផ្តល់សេវាកម្មដល់អតិថិជន

៣. ចងសម្ព័ន្ធជាមួយភាគីពាក់ពន្ធ័

- រួមមានភាគីដូចជា អ្នកភាគហ៊ុន អាជ្ញាធរ ហិរញ្ញវត្ថុ និងអតិថិជន
- ជួបប្រជុំ និងរាយការណ៍ដល់ក្រុមហ៊ុនមេ (Shinhan Financial Group)

៤. ត្រួតពិនិត្យហានិភ័យ និងគោលនយោបាយ Compliance

- រៀបចំគោលនយោបាយស្តង់ដាធនាគារ
- ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ និងនីតិវិធី

៥.ភារកិច្ច (Responsibilities) នៃគណៈគ្រប់គ្រង

- រៀបចំផែនការអាជីវកម្ម សិក្សាស្ថានភាពទីផ្សារ និងប្រកួតប្រជែង
- ត្រួតពិនិត្យថវិកា ការវិភាគចំណូលចំណាយ និងផលចំណេញ
- កំណត់គោលនយោបាយ HR ការជ្រើសរើស បណ្តុះបណ្តាល និងលើកទឹកចិត្តបុគ្គលិក
- ការអភិវឌ្ឍប្រព័ន្ធចាត់ចែងហានិភ័យសេដ្ឋកិច្ច ប្រតិបត្តិ និងច្បាប់
- ធានាគោរពគោលការណ៍គ្រប់គ្រងល្អប្រកាន់យុត្តិធម៌ និងភាពថ្លៃថ្នូរ

## ៣.២ ប្រភេទអតិថិជនដែលធនាគារ ស៊ិនហាន ត្រូវរៀបចំឥណទានឡើងវិញ

### ៣.២.១ លក្ខខណ្ឌអតិថិជន

➢ លក្ខខណ្ឌដែលអតិថិជនត្រូវមាន

១. មូលហេតុពិតប្រាកដនៃការខកខាកសងបំណុល

- ជួបបញ្ហាហិរញ្ញវត្ថុបណ្តោះអាសន្ន
- បញ្ហាសេដ្ឋកិច្ច ឬជំងឺជាតិ (COVID-19)
- បញ្ហាផ្ទាល់ខ្លួន (ឈឺ, គ្រោះថ្នាក់, បាត់បង់ការងារ)

២. បញ្ហាសមត្ថភាពសងវិញនៅពេលអនាគត

- មានចំណូល ឬផែនការច្បាស់លាស់សម្រាប់សង
- ឯកសារបង្ហាញពីសមត្ថភាពសងលើកក្រោយ ( Financial projection, ការងារថ្មី, ប្រាក់ចំណូល)

៣. បង្ហាញចេតនាល្អក្នុងការសងបំណុល

- មិនរត់កិច្ចខ្លួនពីការទំនាក់ទំនងជាមួយធនាគារ
- ឆ្លើយតបលឿន និងឧស្សាហ៍ចូលរួមពិភាក្សាជាមួយភ្នាក់ងារ

៤. មានប្រវត្តិសងល្អកន្លងមក

- ឥណទានសងត្រឹមត្រូវ ឬមានការសងទោះជាប្រញាប់
- មិនមានប្រវត្តិការរំលងការសងជាប្រចាំ

៥. ឯកសារទាំងអស់ត្រូវតែបំពេញគ្រប់គ្រាន់

- សំណើរ ( application/request letter )
- ឯកសារបង្ហាញពីចំណូល ឬវិស័យអាជីវកម្ម
- ឯកសារចុងក្រោយស្ដីពីស្ថានភាពសេដ្ឋកិច្ច
- អត្តសញ្ញាណប័ណ្ណ និងឯកសារផ្ទាល់ខ្លួនផ្សេងៗ
- បញ្ជីបង់ប្រាក់ពីមុន

៦. មានការយល់ព្រមពីអ្នកធានា ( បើមាន )

- អ្នកធានាត្រូវព្រមព្រៀងស្ដីពីលក្ខខណ្ឌថ្មី។

➢ លក្ខខណ្ឌដែលអតិថិជនមិនគួរមាន

- បាត់ទំនាក់ទំនងជាមួយធនាគារ
- មិនបង្ហាញចេតនាសងបំណុល
- ស្ថានភាពហិរញ្ញវត្ថុអស្ថេរភាពយ៉ាងខ្លាំង
- បំភ្លេច ឬបង្ខំឲ្យធនាគាររៀបចំឥណទានឡើងវិញដោយគ្មានមូលហេតុច្បាស់លាស់។

**៣.២.២ យុទ្ធសាស្ត្ររបស់ធនាគារ**

ដោយសារតែមានការមើលឃើញពីបញ្ហាប្រឈមរបស់អតិថិជនដែលកំពុងតែជួបប្រទះ ដូច្នេះ ធនាគារបានរៀបចំយុទ្ធសាស្ត្រសំខាន់ៗជាច្រើនដូចជា៖

១. យុទ្ធសាស្ត្រកែតម្រូវឥណទាន (Loan Restructuring Strategy)

- ផ្តល់នូវជម្រើសដល់អតិថិជនដូចជា៖
  - បន្ថយការប្រាក់
  - ពន្យាពេលបង់ប្រាក់
  - បែងចែកការសងជាដំណាក់កាល
- បន្តទាក់ទាញអតិថិជន និងកាត់បន្ថយការខាតបង់បំណុល

២. យុទ្ធសាស្ត្រទំនាក់ទំនងអតិថិជន

- បង្កើតមណ្ឌល Laon Recovery Center ឬ Hardship Unit ដើម្បីទទួលពាក្យសុំជំនួយ
- ចូលទៅពិភាក្សាផ្ទាល់ជាមួយអតិថិជន
- ផ្តល់ព័ត៌មាន និងឯកសារណែនាំអំពីជម្រើសដែលមាន

៣. យុទ្ធសាស្ត្រវាយតម្លៃហានិភ័យបន្ត (Continuous Risk Assessment Strategy)

- តាមដានស្ថានភាពអតិថិជនជាប្រចាំ
- ប្រើប្រព័ន្ធកុំព្យូទ័រ (Credit Scoring Model) ដើម្បីវាយតម្លៃសមត្ថភាពសងនាពេលក្រោយ
- បែងចែកអតិថិជនតាមកម្រិតហានិភ័យ (High, Medium, Low)

៤.យុទ្ធសាស្ត្រសម្រួលច្បាប់ និងភាពស្មោះត្រង់ (Regulatory & Transparency Strategy)

- រៀបចំការរាយការណ៍ទៅធនាគារជាតិ (NBC)
- ធានាថាគ្រប់ការរៀបចំឥណទានឡើងវិញមានឯកសារផ្លូវការ
- គោរពច្បាប់ NBC ស្តីពី Loan Classification & Provisioning

៥.យុទ្ធសាស្ត្រសម្រួលបច្ចេកវិទ្យា (Digital/ Teachable Strategy)

- ផ្តល់ជម្រើសឱ្យអតិថិជនដាក់សំណើតាមប្រព័ន្ធអេឡិចត្រូនិក
- ប្រើ CRM (Customer Relationship Management) ដើម្បីតាមដានអតិថិជនមានបញ្ហា
- ប្រើ AI ឬ Machine Learning សម្រាប់ព្យាករណ៍ហានិភ័យនាពេលអនាគត

➢ គោលដៅរបស់យុទ្ធសាស្ត្រនេះ
  - រក្សាទំនាក់ទំនងអតិថិជនរយៈពេលវែង
  - បង្កើនភាពទុកចិត្តលើធនាគារ
  - គាំទ្រពិធីប្រកបដោយទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុ

**៣.២.៣ ដំណើរនៃការអនុម័ត**

ដំណើរការនេះត្រូវបានដឹកនាំដោយ ផ្នែកឥណទាន និងថ្នាក់ដឹកនាំធនាគារ ដោយផ្អែកលើគោលការណ៍ថែរក្សាបំណុលសមត្ថភាពសង និងការគ្រប់គ្រងហានិភ័យ។ដំណើរការនៃការអនុម័តរៀបចំឥណទានទាំងអស់នោះរួមមាន៖

១. ទទួលសំណើពីអតិថិជន

- អតិថិជនដាក់សំណើសុំជាផ្លូវការ (Request Letter)
- ផ្តល់ឯកសារគាំទ្រ
  - របាយការណ៍ចំណូល/ចំណាយ
  - ព័ត៌មានអាជីវកម្ម
  - ឯកសារពាក់ព័ន្ធនឹងការលំបាក ( សំបុត្រពេទ្យ, លិខិតបញ្ជាក់ពីកន្លែងធ្វើការ...)
  - បញ្ជីបង់ប្រាក់ពីមុន

២. ពិនិត្យឯកសារជាមុន (Pre-Screening)

- បុគ្គលិកឥណទានត្រួតពិនិត្យភាពគ្រប់គ្រាន់នឯកសារ
- ផ្តល់ពាក្យសម្ភាសន៍ដំបូងដើម្បីយល់ពីមូលហេតុ

៣. វាយតម្លៃសមត្ថភាពសង និងហានិភ័យ

- វិភាគ
  - Cash Flow
  - Collateral (ទ្រព្យធានា)
  - ប្រវត្តិសងបំណុល
  - Credit Scoring
- កំណត់ថ្នាក់ NPL និងគ្រប់លក្ខខណ្ឌសម្រាប់ Loan Classification

៤. រៀបចំផែនការរៀបចំឥណទានឡើងវិញ

- បុគ្គលិកឥណទានស្នើៈ
  - បន្ថយអត្រាការប្រាក់
  - បន្ថែមរយៈពេលសង
  - បន្ថយការបង់ប្រចាំខែ
  - ចំណាយពេលទទួលពិនិត្យលើសំណើ ១-២ សប្តាហ៍ (ហើយអាចបន្ថែម ប្រសិនបើសំណើស្មុគស្មាញ)

៤. ដាក់ស្នើទៅក្រុមប្រឹក្សាឥណទាន (Credit Committee)

- សំណើត្រូវបានត្រៀមជារបាយការណ៍ជាសក្ខីបត្រ
- ផ្ញើទៅថ្នាក់គ្រប់គ្រង ឬក្រុមប្រឹក្សាឥណទានដើម្បីៈ
  - វាយតម្លៃឡើងវិញ
  - សម្រេច ឬបដិសេធសំណើ

៦. ការអនុម័ត (Approval)

- ប្រសិនបើបានអនុម័ត
  - បង្កើតកិច្ចសន្យាថ្មី
  - ចេញតារាងបង់ប្រាក់ថ្មី
- ប្រសិនបើបដិសេធ
  - អាចផ្តល់មតិ ផ្តល់ជំនួយផ្សេងទៀត (Ex: debt workout, legal action)

៧. ចុះហត្ថលេខា និងអនុវត្ត

- អតិថិជន និងអ្នកធានាចុះហត្ថលេខាលើកិច្ចសន្យាថ្មី
- បញ្ចូលព័ត៌មានថ្មីក្នុងប្រព័ន្ធ Core Banking
- ចាប់ផ្តើមការបង់សងតាមលក្ខខណ្ឌថ្មី
- តាមដាន និងវាយតម្លៃបន្ត

- បុគ្គលិកត្រូវតាមដានការបង់ប្រចាំខែ
- ប្រសិនបើមានបញ្ហាបន្ត អាចពិចារណាវិធីដោះស្រាយបន្ថែម (Legal Collection, Asset Recovery)

## ៣.៣ ផលប្រយោជន៍នៃការរៀបចំឥណទានឡើងវិញ

### ៣.៣.១ ផលប្រយោជន៍ចំពោះធនាគារ

### ក.កាត់បន្ថយហានិភ័យនៃការបាត់បង់ឥណទាន

ដោយការរៀបចំឥណទានឡើងវិញ ធនាគារអាចជួយអតិថិជនដែលលំបាកបង់ប្រាក់ក្នុងលក្ខខណ្ឌចាស់ ដោយផ្តល់លក្ខខណ្ឌថ្មីឲ្យសមរម្យ។វាជួយឲ្យអតិថិជនបន្តបង់បំណុលបាន និងធនាគារមិនបាត់បង់ប្រាក់ដើម និងការប្រាក់។ជាជំហានសំខាន់ក្នុងការការពារការខាតបំណុល និងបន្តរក្សាទ្រព្យសម្បត្តិ។

- នៅពេលអតិថិជនមិនអាចបន្តបង់ប្រាក់បានតាមលក្ខខណ្ឌដើមនោះហានិភ័យនៃបំណុលអសកម្ម (NPL) និងការបាត់បង់ប្រាក់ដើមកើនឡើង។
- ដោយធ្វើការរៀបចំឥណទានឡើងវិញ ធនាគារអាចផ្តល់លក្ខខណ្ឌថ្មី ដែលអតិថិជនអាចយកចិត្តទុកដាក់បង់បានវិញ
- ជួយបន្ថយហានិភ័យក្នុងការខាតបំណុល និងការចំណាយពេលធ្វើការប្រមូលបំណុល (Loan Recovery)
- ជៀសវាងការបាត់បង់ប្រាក់ដើម
- ទទួលបានការប្រាក់បានវិញទោះយឺត
- រៀបចំការសងឱ្យសមស្របតាមសមត្ថភាពអតិថិជន

វិធីជាវិធានការរួបរួមក្នុងការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និងជាជម្រើសល្អជាងការលក់បំណុលឱ្យក្រុមហ៊ុនប្រមូលបំណុល ដែលអាចធ្វើឱ្យតម្លៃបំណុលបាត់បង់ជាច្រើនភាគរយ។

### ខ.បន្តទំនាក់ទំនងល្អជាមួយអតិថិជន

ការផ្តល់ឱកាសឱ្យអតិថិជនរៀបចំឥណទានឡើងវិញបង្ហាញថាធនាគារយល់ដឹង និងផ្តល់សេវាកម្មមួយបែប ក្នុងចំណោមអង្គភាពដែលគាំទ្រអតិថិជនក្រោមស្ថានភាពលំបាក។ជួយបង្កើនភាពស្មោះត្រង់ និងភាពស្ម័គ្រចិត្តក្នុងការប្រើប្រាស់សេវាធនាគារ។

- ពេលអតិថិជនប្រឈមបញ្ហាហិរញ្ញវត្ថុ បើធនាគារផ្តល់ឱកាសអោយអតិថិជនកែប្រែសេវាឥណទានដូចជាបន្ថយប្រាក់បង់ប្រចាំខែ ឬពន្យារពេលបង់ប្រាក់ នោះធនាគារបង្ហាញពីភាពយល់ដឹងនិងឯកភាព
- ជួយអោយអតិថិជនមានទំនុកចិត្តលើធនាគារ ហើយបន្តជាអតិថិជនក្នុងរយៈពេលវែង។ (ឧ.អ្នកខ្ចីមិនអាចបង់តាមលក្ខខណ្ឌចាស់បាន តែធនាគារត្រួតពិនិត្យលក្ខខណ្ឌសហការថ្មីជាជម្រើសឱ្យអតិថិជនសងបន្ត)។
- ទាក់ទាញអតិថិជនឱ្យបន្តប្រើសេវាផ្សេងៗ
- ការស្នើសុំឥណទានផ្សេងទៀតកាន់តែងាយស្រួល

ឧទាហរណ៍៖ អតិថិជនដែលធនាគារជួយសងកាលណាពិបាក នឹងមាននិស្ស័យខ្ពស់ក្នុងការរក្សាគណនី ឬប្រើសេវាហិរញ្ញវត្ថុច្រើនជាងមុន។

**គ.រក្សាប្រាក់ចំណូលពីការប្រាក់**

បើឥណទានក្លាយជាឥណទានអសកម្ម ធនាគារនឹងបាត់បាត់ប្រាក់ប្រចាំខែ ហើយអាចបាត់បង់ប្រាក់ដើមផងដែរ។

- ជំនួសអោយធនាគារបាត់បង់ប្រាក់ចំណេញពេញលេញដោយសារអតិថិជនមិនមានលទ្ធភាពក្នុងការបង់ប្រាក់ត្រឡប់មកវិញក្នុងអំឡុងធ្លាក់ចុះនៃប្រាក់ចំណូល។
- ធនាគារនៅតែមានចំណូលដដែលទោះបីជាសេដ្ឋកិច្ចកំពុងធ្លាក់ចុះក៏ដោយ។

**ឃ.បង្កើតភាពទុកចិត្តក្នុងប្រព័ន្ធហិរញ្ញវត្ថុ**

ការចូលរួមចំណែកផ្តល់ដំណោះស្រាយប្រកបដោយការទទួលខុសត្រូវ បង្ហាញថាធនាគារមានទំនួលខុសត្រូវ និងយកចិត្តទុកដាក់ផ្តល់ស្ថានភាពហិរញ្ញវត្ថុរបស់សង្គម។ ជួយពង្រឹងភាពទុកចិត្តពីសាធារណជន និងអាជ្ញាធររដ្ឋ។

- ធនាគារមានគោលនយោបាយដែលអាចបត់បែនតាមស្ថានភាពពិតរបស់អតិថិជន
- ធ្វើអោយសាធារណជនជឿជាក់ថាធនាគារមិនគ្រាន់តែគិតពីប្រាក់ចំណេញ ប៉ុន្តែថែមទាំងយកចិត្តទុកដាក់ពីសុខមាលភាពហិរញ្ញវត្ថុរបស់អតិថិជនផងដែរ។ (ឧ.នៅពេលមានវិបត្តិសេដ្ឋកិច្ច ដូចជាពេលកូវីដ-១៩ ការរៀបចំឥណទានឡើងវិញជួយបន្តស្ថិរភាពក្នុងប្រព័ន្ធហិរញ្ញវត្ថុ។

**ង.បន្ថយកម្រិតឥណទានអសកម្ម**

ការរៀបចំឥណទានឡើងវិញអាចជួយក្នុងការពន្យារពេល ឬបន្ថយការបែងចែកឥណទានជាឥណទានអសកម្ម ដែលជាកត្តាមួយប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ និងការត្រួតពិនិត្យរបស់ធនាគារជាតិក្នុងការប្រកាសសមតុល្យរបាយការណ៍។

- ឥណទានអសកម្មជាបំណុលដែលមិនសងលើស ៩០ថ្ងៃ។ការរៀបចំឥណទានឡើងវិញអាចជួយឱ្យធនាគាររៀបចំចំណាត់ថ្នាក់។
- បង្កើនសមត្ថភាពធនាគារដើម្បីទទួលបានជំនួយឥណទានថ្មីពីធនាគារជាតិ ឬភាគីផ្សេងទៀតដោយសារកម្រិត NPL ធ្លាក់ចុះ។

៣.៣.២ ផលប្រយោជន៍ចំពោះអតិថិជន

**ក.បន្តសងឥណទានដោយងាយស្រួល**

តាមរយៈការរៀបចំឥណទានឡើងវិញ អតិថិជនអាចទទួលបានបានលក្ខខណ្ឌសងប្រាក់ថ្មីដែលសមរម្យនឹងស្ថានភាពបច្ចុប្បន្ន រួមទាំងការពន្យារពេលសង និងការបន្ថយប្រាក់សងប្រចាំខែ។ វាធ្វើឱ្យអតិថិជនមានលទ្ធភាពបន្តសងបានដោយមិនចាំបាច់ដោះសោធនធាន ឬបាត់បង់អចលនទ្រព្យ។

- ប្រសិនបើអតិថិជនកំពុងជួបបញ្ហា ជាពេលបណ្តោះអាសន្ន ការរៀបចំឥណទានឡើងវិញអាចជួយពន្យារពេល ឬកាត់បន្ថយប្រាក់សងប្រចាំខែ
- វាធ្វើឱ្យអតិថិជនមានសមត្ថភាពបន្តសងដោយមិនបាក់បែក និងគ្មានការប៉ះពាល់ដល់ទ្រព្យសម្បត្តិដាក់ធានា។
- ជួយរំលស់តែការប្រាក់សិនជាបណ្តោះអាសន្ន

ឧទាហរណ៍៖ បុរសម្នាក់បាត់បង់ការងារ។ ប្រាក់សងធម្មតា ៣០០ដុល្លារ/ខែ ក្លាយទៅជា ១០០ដុល្លារ/ខែ ដោយពន្យារពេលសងបួនឆ្នាំបន្ថែម។ នេះធ្វើឱ្យគាត់បន្តសងបានដោយមិនបញ្ចាញទ្រព្យដាក់ធានា។

**ខ.បន្ថយបន្ទុកហិរញ្ញវត្ថុ**

ការបន្ថយកំណត់ប្រាក់សងប្រចាំខែ ឬអត្រាការប្រាក់អាចធ្វើឱ្យអតិថិជនសន្សំថវិកាបានប្រសើរឡើង និងគ្រប់គ្រងស្ថានភាពហិរញ្ញវត្ថុផ្ទាល់ខ្លួនបានកាន់តែងាយស្រួល។

- សន្សំថវិកាសម្រាប់ការចាំបាច់ (ឧទាហរណ៍៖ ថ្លៃសុខភាព ការអប់រំ)
- អាចកាត់បន្ថយប្រាក់សងប្រចាំខែ ឬពន្យារពេលសង ដើម្បីឱ្យអតិថិជនមានកម្រៃសាច់ប្រាក់ប្រើប្រាស់ប្រចាំថ្ងៃ។
- ជួយឱ្យក្រុមគ្រួសារមានសុខភាពផ្លូវចិត្តល្អជាងមុន

នៅក្នុងប្រទេសកម្ពុជា ប្រជាជនជាច្រើនមានចំណូល មធ្យម-ទាប។ ការរីករាលដាលនៃវិបត្តិសេដ្ឋកិច្ច ឬជំងឺអាចធ្វើឱ្យក្រុមគ្រួសារជួបវិបត្តិហិរញ្ញវត្ថុ។ ការរៀបចំឥណទានឡើងវិញក៏ជាផ្នែកមួយក្នុងការជួយទៅដល់សង្គមដ៏សំខាន់។

**គ.បន្ធូរបន្ថយអត្រាការប្រាក់**

ក្នុងករណីជាក់លាក់ណាមួយ ធនាគារអាចពិចារណាបន្ថយអត្រាការប្រាក់ ឬប្តូរជាទម្រង់អត្រាដែលមានតម្រង់យ៉ាងច្បាស់ ដូចជាពីអត្រាខ្ពស់ទៅអត្រាទាប ឬកាត់បន្ថយការប្រាក់។ នេះធ្វើឱ្យអតិថិជនសងប្រាក់តិចជាងមុន និងសន្សំលើចំណាយអស់រយៈពេលវែង។

- បង្កើនការទំនាក់ទំនងឥណទានជាប្រចាំ
- កាត់បន្ថយចំណាយសរុបក្នុងរយៈពេលវែង
- ជួយឱ្យអតិថិជនអាចរៀបចំផែនការហិរញ្ញវត្ថុដោយច្បាស់លាស់។

ឧទាហរណ៍៖ អតិថិជនម្នាក់បានស្នើឱ្យកាត់ការប្រាក់ពី ១៨% ទៅ ១២% ក្រោមគម្រោងជួយអតិថិជន។ ការប្រាក់សរុបអស់រយៈពេល ៥ឆ្នាំ បានកាត់បន្ថយពី ៣០០០ដុល្លា ចុះមក ១៨០០ដុល្លា។

**ឃ.រក្សាទំនាក់ទំនងល្អជាមួយធនាគារ**

ការរួមដំណើរការជាមួយធនាគារដើម្បីស្វែងរកដំណោះស្រាយ ជាការបង្ហាញនូវភាពទំនួលខុសត្រូវ និងឆន្ទៈក្នុងការសងបំណុល។

- ពង្រឹងភាពជឿជាក់ពីធនាគារ
- អាចស្នើសុំឥណទានថ្មីបានងាយ
- ទទួលបានអត្ថប្រយោជន៍សេវាហិរញ្ញវត្ថុផ្សេងៗ៖ ប័ណ្ណឥណទាន, ប្រព័ន្ធផ្ទេរប្រាក់, ឥណទានសម្រាប់អាជីវកម្ម។

នៅក្នុងបណ្ដាញហិរញ្ញវត្ថុទំនើប "Credit Bahavior" របស់អតិថិជន គឺជាគន្លឹះសំខាន់ក្នុងការផ្តល់ឥណទានជាបន្ត។

**ង.រក្សាប្រវត្តិឥណទានល្អ**

ប្រវត្តិឥណទាន គឺជាឯកសារសំខាន់សម្រាប់ពិនិត្យសមត្ថភាពហិរញ្ញវត្ថុអតិថិជន។ បើការសងមិនបានគោរព នោះប្រវត្តិឥណទាននឹងខូច ហើយអាចមានការបដិសេធច្រើននៅពេលក្រោយ។

- មានឱកាសស្នើសុំឥណទាន ឬប័ណ្ណឥណាតទានថ្មី
- ទទួលបានលក្ខខណ្ឌសមរម្យ (អត្រាការប្រាក់ទាប/ចំនួនខ្ពស់)
- ជាកត្តាចាំបាច់សម្រាប់ការវិនិយោគ ឬសាងសង់អនាគតហិរញ្ញវត្ថុ

ឧទាហរណ៍៖ អ្នកជាម្ចាស់អាជីវកម្មត្រូវការរថយន្តសម្រាប់ដឹកទំនិញ។ ប្រវត្តិឥណទានល្អធ្វើឱ្យធនាគារអនុម័តឥណទានបានលឿន និងមានអត្រាការប្រាក់សមរម្យ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១. វិភាគលើចំណុចខ្លាំង

- បទពិសោធន៍ខ្ពស់ក្នុងវិស័យឥណទាន
  - ធនាគារស៊ិនហានមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងការបញ្ជាក់ ឬផ្តល់ឥណទាន ដោយមានប្រព័ន្ធគ្រប់គ្រងហានិភ័យល្អ។ វាជួយឲ្យការរៀបចំឥណទានឡើងវិញកើតមានប្រសិទ្ធភាព។
  - ការសម្រេចចិត្តស្របស្ថានភាពហិរញ្ញវត្ថុអតិថិជន នឹងបង្កើនឱកាសសងបំណុលបានវិញ។
- សមត្ថភាពធនធាន និងបច្ចេកវិទ្យាដែលមានប្រសិទ្ធភាព
- ការប្រើប្រាស់ប្រព័ន្ធ Core Banking និងសេវាឌីជីថល (Mobile & Internet Banking) អនុញ្ញាតឲ្យធនាគារប្រមូលព័ត៌មានបានរហ័ស និងត្រឹមត្រូវក្នុងការវិភាគស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន។
  - វាធានាបាននូវការរៀបចំឥណទានឡើងវិញតាមស្តង់ដារ និងអាចតាមដានយ៉ាងមានប្រសិទ្ធភាព។
- សេវាកម្មផ្ទាល់ខ្លួន និងបត់បែនតាមស្ថានភាពអតិថិជន
  - ធនាគារស៊ិនហានព្យាយាមផ្តល់ជម្រើសរៀបចំឥណទានឡើងវិញដែលសមរម្យសម្រាប់អតិថិជនក្នុងករណីមានបញ្ហាជាក់លាក់ (e.g. COVID-19, បញ្ហាជីវភាពសេដ្ឋកិច្ច)។
  - វាធ្វើឲ្យអតិថិជនមានទំនុកចិត្ត និងបន្តទំនាក់ទំនងជាអ្នកខ្ចីប្រាក់រយៈពេលវែង។
- ភាពជឿជាក់នៃធនាគារ
  - ជាធនាគារដែលមានស្ថាបនាបានយូរឆ្នាំ មានឥទ្ធិពលលើទីផ្សារ និងទំនុកចិត្តខ្ពស់ពីសាធារណៈ ដោយនេះធ្វើឲ្យអតិថិជនស្នើសុំរៀបចំឥណទានឡើងវិញដោយកាន់តែជឿជាក់។

## ៤.២. វិភាគលើចំណុចខ្សោយ

- ដំណើរការដែលពិបាក និងចំណាយពេលយូរ
  - បើទោះបីមានប្រព័ន្ធទំនើប ការរៀបចំឥណទានឡើងវិញនៅតែតម្រូវឲ្យអតិថិជនផ្តល់ឯកសារច្រើន និងពេលវេលាច្រើន។
  - ធ្វើឲ្យអតិថិជនខ្លះធុញថប់ ឬសម្រេចចិត្តមិនចង់ស្នើសុំឡើយ។
- ភាពគ្មានលក្ខណៈបត់បែនសម្រាប់អតិថិជនខ្លះ
  - ទោះបីមានសេវាបត់បែនជាច្រើនក៏ដោយ ការរៀបចំឡើងវិញត្រូវអនុវត្តតាមស្តង់ដារខ្ជាប់ខ្ជួនរបស់ធនាគារ ដែលអាចមិនសមរម្យសម្រាប់អតិថិជនជាបុគ្គល ឬសហគ្រាសខ្នាតតូចមួយចំនួន។
  - ពីព្រោះធនាគារត្រូវការសន្សំសន្សើមចំពោះហានិភ័យដែលប៉ះពាល់ដល់សុខស្ថានហិរញ្ញវត្ថុរបស់ខ្លួន។
- ការបង្ហាញព័ត៌មានមិនទូលំទូលាយ
  - អតិថិជនជាច្រើនមិនដឹងពីជម្រើសឥណទានឡើងវិញទាំងសារព័ត៌មាន ឬគេហទំព័រមិនបង្ហាញបានច្បាស់លាស់
  - វាធ្វើឱ្យអតិថិជនខ្វះការយល់ដឹង និងខកខានឱកាសក្នុងការអភិវឌ្ឍន៍ហិរញ្ញវត្ថុរបស់ខ្លួន
- ការរិះគន់ពីសាធារណៈនៅពេលមានការពន្យាពេល

- ក្នុងករណីដែលធនាគាររំលេចការជួយអតិថិជន (ដូចជាពេលកូវីដ-១៩) ប៉ុន្តែការអនុវត្តនៅមានការជាប់គាំងសូមភាពលើបច្ចេកទេស ឬមនុស្សខាងក្នុង នឹងនាំឲ្យអតិថិជនបាត់បង់ទំនុកចិត្ត។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១.សេចក្តីសន្និដ្ឋាន

ធនាគារ ស៊ិនហាន បានបង្ហាញពីសមត្ថភាពគ្រប់គ្រងឥណទានឡើងវិញយ៉ាងមានប្រសិទ្ធភាព តាមរយៈគ្រប់គ្រងហានិភ័យយ៉ាងជៀសវាង និងផ្តល់ជម្រើសបត់បែនសម្រាប់អតិថិជន។ ការរៀបចំឥណទានឡើងវិញ (loan restructuring) បានផ្តល់អត្ថប្រយោជន៍ជាច្រើនដូចជា៖

- ជួយឱ្យអតិថិជនបន្តការសងបំណុលក្នុងស្ថានភាពធូន់ធ្ងរ។
- រក្សាបានទំនាក់ទំនងល្អជារយៈពេលវែងជាមួយអតិថិជន។
- ជួយអោយធនាគារបន្តរក្សាកម្រិតឥណទានល្អ ហើយបន្ថយការបាត់បង់ពីបំណុលអនាគត (non-performing loans) ។

ដោយសារតែមានការប្រើប្រាស់បច្ចេកវិទ្យា និងបទពិសោធន៍វែងក្នុងវិស័យហិរញ្ញវត្ថុ ធនាគារស៊ិនហានអាចកសាងស្ថេរភាពសេដ្ឋកិច្ចតូចៗរបស់អតិថិជន និងជួយទប់ស្កាត់ហានិភ័យរបស់ខ្លួនផងដែរ។

## ៥.២.ការផ្តល់អនុសាសន៍

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការរៀបចំឥណទានឡើងវិញ និងជៀសវាងភាពបាត់បង់ទំនុកចិត្តពីអតិថិជន ដូចជា៖

- ឧបត្ថម្ភដំណើរការឲ្យមានភាពរហ័ស និងងាយស្រួល
  - អភិវឌ្ឍប្រព័ន្ធស្នើសុំឥណទានឡើងវិញតាមបច្ចេកវិទ្យាឌីជីថល ដែលអនុញ្ញាតឲ្យអតិថិជនបញ្ជូនឯកសារតាមប្រព័ន្ធលើអ៊ីនធឺណិត ដើម្បីកាត់បន្ថយពេលវេលា និងការចំណាយ។
- ពង្រឹងការបង្ហាញព័ត៌មាន និងការផ្សព្វផ្សាយ
  - ផ្តល់ព័ត៌មានអំពីជម្រើសឥណទានឡើងវិញជាច្បាស់លាស់ តាមរយៈគេហទំព័រ សង្គមបណ្តាញ និងសេវាផ្ទាល់ខ្លួន ដើម្បីអភិវឌ្ឍការយល់ដឹងរបស់អតិថិជន។
- បន្ថែមភាពបត់បែនសម្រាប់អតិថិជន SME និងបុគ្គល
  - បង្កើតម៉ូឌែលឥណទានឡើងវិញឯកភាព (customized) សម្រាប់អតិថិជនខ្នាតតូច ដែលមានតម្រូវការពិសេសផ្ទាល់ខ្លួន ដើម្បីឲ្យមានភាពសមរម្យនឹងស្ថានភាពពិត។
- បណ្តុះបណ្តាលបុគ្គលិកអោយមានសមត្ថភាពក្នុងការប្រឹក្សាហិរញ្ញវត្ថុ
  - បុគ្គលិកគួរត្រូវបានបណ្តុះបណ្តាលឲ្យមានជំនាញក្នុងការវិភាគស្ថានភាពហិរញ្ញវត្ថុអតិថិជន និងផ្តល់ដំណោះស្រាយដែលអាចអនុវត្តបានក្នុងជំម្រើសឥណទានឡើងវិញ។

# ឯកសារយោង

## ១.ដកស្រង់ចេញពីសៀវភៅ


- វិទ្យាស្ថាន វ៉ាន់ដា. (២០១៧). *សៀវភៅរូបិយវត្ថុ និងធនាគារ.* បោះពុម្ពឆ្នាំ២០១៧. ទំព័រទី២. ភ្នំពេញ។
- ហេង ប៊ុននី ,លឿន គាត្ថា, កែវ សានីត, ហ៊ុល ហៀងម៉ូនីតា, តិល ផាវ៉ា. (ឆ្នាំ២០២២). ដំណឹងននៃការផ្តល់ឥណទានរបស់ធនាគារឯកទេសឌីជីប៊ី. សារណាថ្នាក់បរិញ្ញបត្រជំនាន់ទី១៩ ជំនាញគណនេយ្យ នៃវិទ្យាស្ថានវ៉ាន់ដា ទំព័រទី៣-១០ ទំព័រទី៣៥


## ២.ដកស្រង់ចេញពីគេហទំព័រ


- TOLA Banking. (2020, July 5). *តើឥណទានជាអ្វី?* Retrieved March, 15 2025 from https://www.facebook.com/share/p/1DkDcay5MB/
- PANHA KH. (2020, October 25). *និយមន័យឥណទាន.* Retrieved March, 15 2025 from https://youtu.be/z35JVQNSHx8?si=nadf_TTNOi778LSZ
- ធនាគារជាតិ. *ប្រវត្តិធនាគារ ?* Retrieved from March, 15 2025 from https://www.nbc.gov.kh/download_files/legislation/prakas_kh/1031b7-00-04.pdf
- ធនាគារជាតិ. ២០២៤. *ការរៀបចំឥណទានឡើងវិញ.* Retrieved from March, 15 2025 from http://www.nbc.gov.kh/download_files/legislation/prakas_kh/B7-024-001_C.L_Circular_ on_ LoanRestructuring_20240829.pdf
- ACADEMIA. Ory Kalip Ory Kalip. *និយមន័យធនាគារ.* Retrieved March, 15 2025 from https://www.academia.edu/31513027/និយមន_យធនាគារ

# ឧបសម្ព័ន




រូបភាពជួបជាមួយគ្រូណែនាំ




រូបភាពពេលចុះទៅសួរព័ត៌មាននៅធនាគារ




ធនាគារស៊ិនហាន សាខាម៉ៅសេទុង